ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំស្តីពី ការកំណត់បែងចែកតំបន់ក្នុងតំបន់ការពារធម្មជាតិ









២០១៧

អ.ក.ធ (២០១៧). គោលការណ៍ណែនាំស្តីពី
ការកំណត់បែងចែកតំបន់ក្នុងតំបន់ការពារធម្មជាតិ

ឯកសារនេះបោះពុម្ពដោយ  អគ្គនាយកដ្ឋានរដ្ឋបាល
ការពារ និងអភិរក្សធម្មជាតិ(អ.ក.ធ) នៃក្រសួងបរិស្ថាន
ដោយមានការគាំទ្រពីមូលនិធិភាពជាដៃគូកាបូន
ព្រៃឈើ និងអង្គការ UNDPកម្ពុជា តាមរយៈ
កម្មវិធីរេដបូកកម្ពុជា

អាសយដ្ឋាន៖ ជាន់ទី២ នៃក្រសួងបរិស្ថាន អគារមរតក
តេជោ ដីឡូលេខ៥០៣ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

FOREST CARBON PARTNERSHIP FACILITY

UNDP
Empowered lives.
Resilient nations.

# គោលការណ៍ណែនាំស្តីពី
# ការកំណត់បែងចែកតំបន់ក្នុងតំបន់ការពារធម្មជាតិ

# សារលិខិត

ក្រសួងបរិស្ថានមានក្តីសោមនស្សរីករាយជាអនេកកប្បការ ដែលអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ បានរៀបចំបង្កើតនូវ «គោលការណ៍ណែនាំស្តីពីការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ» សម្រាប់ជាមូលដ្ឋានដ៏សំខាន់ ក្នុងការកំណត់បែងចែកតំបន់គ្រប់គ្រងទាំងបួន ដូចមានចែងក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិជំពូកទី៤ មាត្រា១១ ស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រង។

គោលការណ៍ណែនាំនេះ នឹងធានាបាននូវសុក្រឹតភាពការងារគ្រប់គ្រងតំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជា និងធ្វើឱ្យប្រសើរឡើងនូវតម្លៃ និងមុខងារប្រព័ន្ធអេកូឡូស៊ី លំនឹងបរិស្ថាន សុខមាលភាពសាធារណៈ ធ្វើឱ្យប្រសើរឡើងនូវជីវភាពសហគមន៍មូលដ្ឋាន ទ្រទ្រង់និរន្តរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ ទាំងនេះជាផលប្រយោជន៍ដ៏ឧត្តុងឧត្តមសម្រាប់មនុស្សគ្រប់ជំនាន់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលសម្បូរធនធានព្រៃឈើ និងជីវចម្រុះ លាតសន្ធឹងពីតំបន់ដីគោក ទឹកសាប និងតំបន់ឆ្នេរសមុទ្រ ដែលមានតួនាទីយ៉ាងសំខាន់ នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងគុណភាពបរិស្ថាន សម្បត្តិវប្បធម៌ធម្មជាតិ ជានិរន្តគ្រប់ជំនាន់។ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ២០១៧-២០៣១ ដើម្បីរួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព រួមមានទាំងការកាត់បន្ថយភាពក្រីក្រពិសេសតាមរយៈការអភិរក្ស និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានជីវៈចម្រុះ ធនធានធម្មជាតិ និងសម្បត្តិវប្បធម៌ធម្មជាតិ ព្រមទាំងសេវាប្រព័ន្ធអេកូឡូស៊ី។ ក្នុងក្របខណ្ឌនៃការអនុវត្តគោលនយោបាយកែទម្រង់ការងារគ្រប់គ្រងធនធានធម្មជាតិ តំបន់ការពារធម្មជាតិបានកើនឡើងពី ២៣តំបន់ មានផ្ទៃដី ៣,២លានហិកតា ទៅ ៥០តំបន់ និងរបៀងអភិរក្សជីវៈចម្រុះ (របៀងអភិរក្សជីវៈចម្រុះឦសាន របៀងអភិរក្សជីវៈចម្រុះឧត្តរ និងរបៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ) មានផ្ទៃដីប្រមាណ ៧,៥លានហិកតា ដែលស្មើនឹង ៤១% នៃផ្ទៃដីប្រទេសកម្ពុជា។

គោលការណ៍ណែនាំនេះ នឹងរួមចំណែកនៃប្រសិទ្ធភាពការគ្រប់គ្រង និងការប្រើប្រាស់ដីព្រៃក្នុងតំបន់ការពារធម្មជាតិ និងធ្វើឱ្យប្រសើរឡើងនូវការចូលរួមពីភាគីពាក់ព័ន្ធ ក្នុងការកំណត់បែងចែកតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ រួមទាំងការងារពង្រឹងការអនុវត្តច្បាប់។

ខ្ញុំមានការជឿជាក់ និងក្តីសង្ឃឹមថា គោលការណ៍ណែនាំ ស្តីពីការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ នឹងជួយផ្តល់នូវសុក្រឹតភាពនៃការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ និងនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានលើគុណភាពបំណិនជីវិតរបស់ប្រជាជនសហគមន៍មូលដ្ឋាន៕

ថ្ងៃសុក្រ ១២កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាក្នុងអណត្តិទី៥ នៃរដ្ឋសភាជាតិ បានដាក់ចេញនូវគោលនយោបាយកែទម្រង់ស៊ីជម្រៅលើការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលមានក្រសួងបរិស្ថានជាស្ថាប័នដឹកនាំអនុវត្តរៀបចំគ្រប់គ្រងតំបន់ការពារធម្មជាតិ ឱ្យមានលក្ខណៈជាប្រព័ន្ធ ស្របតាមប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងទីតាំងភូមិសាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចជានានិរន្តរភាពអេកូឡូស៊ី សេដ្ឋកិច្ច-សង្គម និងបរិស្ថាន ដែលជាស្នូលមូលដ្ឋានគ្រឹះនៃសុខមាលភាពសាធារណៈ។

ដោយទទួលបានការដឹកនាំ និងចង្អុលទិសដោយ **ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន** អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ បានដឹកនាំរៀបចំឯកសារគោលការណ៍ណែនាំស្តីពី ការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងគោលបំណងកំណត់ឱ្យបានច្បាស់លាស់អំពីក្របខ័ណ្ឌគតិយុត្ត ការងារគ្រប់គ្រង បច្ចេកទេស និងផ្អែកលើបទពិសោធន៍ និងការអនុវត្តល្អៗពីបណ្តាប្រទេសនានាក្នុងតំបន់ និងពិភពលោក។ ទាំងនេះសំដៅជានាឱ្យបាននូវប្រសិទ្ធិភាព និងប្រសិទ្ធិផលគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិដែលជាមូលដ្ឋានគ្រឹះក្នុងការចូលរួមអភិវឌ្ឍប្រកបដោយចីរភាព បង្កើនកម្រិតជីវភាពរបស់សហគមន៍មូលដ្ឋាន កាត់បន្ថយការពឹងផ្អែកអាស្រ័យលើផលព្រៃឈើ និងជានាបាននូវតុល្យភាពរវាងការបំភាយ និងការស្រូបឧស្ម័នផ្ទះកញ្ចក់ពីវិស័យព្រៃឈើ។

ឯកសារគោលការណ៍ណែនាំនេះ រៀបចំឡើងដើម្បីសម្រេចគោលដៅដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រជាតិ សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលត្រូវសម្រេចឱ្យបាននូវការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធិភាព ប្រសិទ្ធិផល និងសមធម៌ ក្នុងគោលបំណងថែរក្សា ការពារ និងលើកកម្ពស់តម្លៃអេកូឡូស៊ី មរតកវប្បធម៌ធម្មជាតិ វប្បធម៌សង្គមមូលដ្ឋាន លើកកម្ពស់ការចូលរួម និងការគាំទ្រពីសហគមន៍មូលដ្ឋាន បង្កើតឱកាសសម្រាប់ចីរភាពវិស័យអេកូទេសចរណ៍ និងអភិវឌ្ឍហិរញ្ញវត្ថុគ្រប់គ្រងតំបន់ការពារធម្មជាតិដោយនិរន្តរភាពព្រមទាំងពង្រឹងប្រសិទ្ធិភាព សហការជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន ដៃគូអភិវឌ្ឍន៍អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល។

គោលការណ៍ណែនាំនេះរៀបចំឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗមួយចំនួនដូចខាងក្រោម៖

- តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិមាន ៤តំបន់ គឺតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍
- លក្ខណវិនិច្ឆ័យផ្អែកអេកូឡូស៊ី សម្រាប់កំណត់បែងចែកតំបន់មាន ៤លក្ខណវិនិច្ឆ័យ រួមមានទីតាំង ទំហំ ទ្រង់ទ្រាយ ឥទ្ធិពលរបស់ជ្រុងនៃតំបន់គ្រប់គ្រង តំណភ្ជាប់ និងជម្រកសមស្រប
- លក្ខណវិនិច្ឆ័យផ្អែកសេដ្ឋកិច្ច-សង្គម រួមមានលទ្ធភាពទ្រទ្រង់នៃធនធានធម្មជាតិ និងលក្ខណៈភូមិសាស្ត្រនៃតំបន់នីមួយៗ
- លក្ខណវិនិច្ឆ័យ សម្រាប់កំណត់តំបន់គ្រប់គ្រងនីមួយៗរួមមាន តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។

ឯកសារនេះ ជាក្របខ័ណ្ឌបច្ចេកទេស និងសង្គម និងជាឧបករណ៍គាំទ្ររយៈពេលវែងក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិឱ្យមានលក្ខខណ្ឌជាប្រព័ន្ធ ធានាបាននូវសុវត្ថិភាពពេញលេញ ចំពោះធនធានជីវៈចម្រុះ មរតកវប្បធម៌ធម្មជាតិ វប្បធម៌សង្គមមូលដ្ឋានដែលយើងគ្រប់ៗគ្នាត្រូវធ្វើជាស្ពានចម្លងបន្តមរតកធម្មជាតិទាំងនេះទៅអ្នកជំនាន់ក្រោយៗទៀត។

គោលការណ៍ណែនាំនេះ ជាមូលដ្ឋានគ្រឹះផ្តល់នូវពុទ្ធិដល់មន្ត្រីមានសមត្ថកិច្ច និងគ្រប់ភាគីពាក់ព័ន្ធដើម្បីចូលរួមកំណត់បែងចែកតំបន់គ្រប់គ្រងឱ្យបានត្រឹមត្រូវ ស្របតាមគោលនយោបាយរាជរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្ត លក្ខខណ្ឌបច្ចេកទេស ក្របខ័ណ្ឌអនុសញ្ញា និងកិច្ចព្រមព្រៀងតំបន់ ឬសកល និងស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗ។

គោលការណ៍ណែនាំនេះ អាចធ្វើបច្ចុប្បន្នភាព ទៅតាមទិន្នន័យវិទ្យាសាស្ត្រ ឬស្ថានភាពជាក់ស្តែងនិន្នាការនៃការវិវឌ្ឍ និងតម្រូវការអភិបាលកិច្ចនៃតំបន់ការពារធម្មជាតិ។

ក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំក្រសួងបរិស្ថាន ថ្នាក់ដឹកនាំ និងមន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ មន្ទីរបរិស្ថានរាជធានី-ខេត្ត លោកបណ្ឌិត Nophea Sasaki អង្គការ Wildlife Alliance អង្គការ UNDP និងអ្នកពាក់ព័ន្ធក្នុងការចូលរួមរៀបចំគោលការណ៍ណែនាំដ៏សំខាន់នេះ៕

ថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧

**អគ្គនាយក**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ ៥៥៦ ប្រ.ក ប.ស្ក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើគោលការណ៍ណែនាំស្តីពី ការកំណត់បែងចែកតំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៩០១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញប្រកាសលេខ ២៥៩ប្រ.កប.ស្ក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋបាលការពារនិងអភិរក្សធម្មជាតិសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅតាមរាជធានី ខេត្ត



អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ ១ -**

ដាក់ឱ្យប្រើគោលការណ៍ណែនាំស្តីពីការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ សម្រាប់ប្រើប្រាស់ក្នុងការកំណត់ បែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គនាយិកានៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានមន្ទីរបរិស្ថានរាជធានី-ខេត្ត និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់នៃក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១២ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ ចំពោះថ្នាក់ដឹកនាំក្រសួងបរិស្ថាន ដែលបានផ្តល់មតិដឹកនាំ និងថ្លែងអំណរគុណចំពោះ ថ្នាក់ដឹកនាំ មន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រុមការងារអ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ ដែលបានខិតខំយកចិត្តទុកដាក់រៀបចំនូវគោលការណ៍ណែនាំស្តីពី ការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ។

សូមសំដែងនូវការកោតសរសើរចំពោះការខិតខំរបស់អង្គការ Wildlife Alliances ដែលបានផ្តល់ជំនួយបច្ចេកទេស និងអង្គការ UNDP និងអង្គការមិនមែនរដ្ឋាភិបាល ដោយបានចូលរួមផ្តល់នូវធាតុចូលសម្រាប់រៀបចំគោលការណ៍ណែនាំនេះឱ្យកាន់តែប្រសើរឡើង។

# មាតិកា


ទំព័រ

**សារលិខិត** ........ i

**អារម្ភកថា** ........ ii

**សន្ទានុក្រម** ........ ix

**១. សេចក្តីផ្តើម** ........ ១

១.១. សាវតា នៃការរៀបចំគោលការណ៍ណែនាំស្តីពី ការកំណត់បែងចែកតំបន់គ្រប់គ្រង ........ ១

១.២. ប្រព័ន្ធតំបន់ការពារធម្មជាតិ ........ ១

១.៣. ការអនុវត្តអនុសញ្ញាអន្តរជាតិ ........ ៣

១.៤. ក្របខណ្ឌច្បាប់ សម្រាប់ការកំណត់បែងចែកតំបន់គ្រប់គ្រង ........ ៤

**២. ចក្ខុវិស័យ** ........ ៤

**៣. បេសកកម្ម** ........ ៤

**៤. គោលបំណង** ........ ៤

**៥. លក្ខណវិនិច្ឆ័យសម្រាប់កំណត់ បែងចែកតំបន់គ្រប់គ្រង** ........ ៤

៥.១. គោលបំណងនៃការគ្រប់គ្រងតំបន់នីមួយៗ ........ ៥

៥.១.១. តំបន់ស្នូល ........ ៥

៥.១.២. តំបន់អភិរក្ស ........ ៥

៥.១.៣. តំបន់ប្រើប្រាស់ដោយចីរភាព ........ ៥

៥.១.៤. តំបន់សហគមន៍ ........ ៥

៥.២. លក្ខណវិនិច្ឆ័យផ្នែកអេកូឡូស៊ី ........ ៦

៥.២.១. ទីតាំង ទំហំ និងទ្រង់ទ្រាយ ........ ៦

៥.២.២. ឥទ្ធិពលរបស់ជ្រុង (ជាយ) នៃតំបន់គ្រប់គ្រង ........ ៦

៥.២.៣. តំណភ្ជាប់ ........ ៦

៥.២.៤. ជម្រកសមស្រប ........ ៦

៥.៣. លក្ខណវិនិច្ឆ័យសេដ្ឋកិច្ច-សង្គម ........ ៧

៥.៤. លទ្ធភាពទ្រទ្រង់នៃធនធានធម្មជាតិ ........ ៧

៥.៥.លក្ខណៈភូមិសាស្ត្រនៃតំបន់នីមួយៗ ........ ៧

**៦. ការកំណត់តំបន់គ្រប់គ្រងនីមួយៗ** ...... ៨
៦.១. តំបន់ស្នូល ...... ៨
៦.១.១. តម្រូវការប្រវែងចម្ងាយ ឬទំហំសម្រាប់ជម្រកសមស្រប ...... ៩
៦.២ តំបន់អភិរក្ស ...... ៩
៦.៣. តំបន់ប្រើប្រាស់ដោយចីរភាព ...... ១០
៦.៤. តំបន់សហគមន៍ ...... ១១
**៧. ជំហានសំខាន់ៗសម្រាប់ការអនុវត្ត** ...... ១២
៧.១. ការបង្កើតក្រុមការងាររៀបចំកំណត់បែងចែកតំបន់គ្រប់គ្រង ...... ១២
៧.២. វិធីសាស្ត្រនៃការសិក្សា ...... ១៣
៧.៣. ការសិក្សាបឋម ...... ១៣
៧.៤. ការសិក្សានៅទីវាល ...... ១៣
៧.៥. បញ្ចប់សេចក្តីព្រាង និងអនុម័ត លទ្ធផលការកំណត់បែងចែកតំបន់គ្រប់គ្រង ...... ១៤
**៨. វិធានការសម្រាប់ការកំណត់បែងចែកតំបន់គ្រប់គ្រងប្រកបដោយប្រសិទ្ធភាព** ...... ១៤
**ឧបសម្ព័ន្ធ១ ៖ សត្វដែលជិតផុតពូជ និងតម្រូវការជម្រក** ...... ១៦
**ឧបសម្ព័ន្ធ២ ៖ តំបន់អាទិភាពសម្រាប់កំណត់តំបន់នីមួយៗ ក្នុងតំបន់ការពារធម្មជាតិ** ...... ១៨
**ឧបសម្ព័ន្ធ៣៖ ឧទាហរណ៍ពីការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងសម្បតិកម្ម តំបន់ការពារធម្មជាតិមួយ** ...... ១៩
**ឧបសម្ព័ន្ធ៤៖ ផែនទីប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ** ...... ២០
**ឯកសារយោង** ...... ២១

# សន្ធានុក្រម

ក្នុងមាត្រា១១ ជំពូកទី៤ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ តំបន់ការពារធម្មជាតិនីមួយៗ បែងចែកចេញជាបួន(៤) តំបន់គ្រប់គ្រង។

**តំបន់ស្នូល៖** ជាតំបន់គ្រប់គ្រងដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិដែលកម្រ ជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គំរាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ។ ការចេញចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិ ក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិជីវចម្រុះ និងបរិស្ថាន ដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន លើកលែងតែក្នុងវិស័យសន្តិសុខ និងការពារជាតិ។

**តំបន់អភិរក្ស៖** ជាតំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូលដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។ ការចេញ ចូលតំបន់នេះ ត្រូវតែមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែង លើកលែងតែមានការចាំបាច់ ក្នុងវិស័យសន្តិសុខ និងការពារជាតិ។ ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះ សម្រាប់ជីវភាពសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលមិនប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យម៉ត់ចត់បំផុតរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។

**តំបន់ប្រើប្រាស់ដោយចីរភាព៖** ជាតំបន់គ្រប់គ្រងដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឱ្យមានការអភិវឌ្ឍ និងសកម្មភាពវិនិយោគនៅក្នុងតំបន់នេះ តាមការស្នើសុំរបស់ក្រសួងបរិស្ថាន ក្រោយពីមានការពិគ្រោះយោបល់ពីបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមច្បាប់ និងនីតិវិធីជាធរមាន។

**តំបន់សហគមន៍៖** ជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍ និងជនជាតិដើមភាគតិច ដែលមានសកម្មភាពស្រាប់ រួមមានលំនៅដ្ឋាន ស្រែ និងចំការ។ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី នៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។ តំបន់ការពារធម្មជាតិនេះ មិនគ្របដណ្តប់ទៅលើការកំណត់ និងការចាត់ចែងគ្រប់គ្រងរបស់អាជ្ញាធរអប្សរា និងអាជ្ញាធរដទៃទៀត ដែលរាជរដ្ឋាភិបាលប្រគល់ភារកិច្ចឱ្យ។

ពាក្យគន្លឹះសំខាន់ផ្សេងទៀតដែលប្រើក្នុងគោលការណ៍ណែនាំនេះមាន៖

យោងតាមអង្គការសហភាពអន្តរជាតិ ដើម្បីការអភិរក្សធម្មជាតិ គឺមាន ប្រភេទនៃតំបន់ការពារធម្មជាតិនានា ដូចជា៖ បម្រុងធម្មជាតិតឹងរឹង(Ia) តំបន់ទីរហោឋាន(Ib) ឧទ្យានជាតិ(II) បូជនីយដ្ឋាន ឬលក្ខណៈធម្មជាតិ(III) តំបន់គ្រប់គ្រងទីជម្រក/បន្តពូជ(IV) តំបន់ការពារទេសភាព/លំហរសមុទ្រ(V) និងតំបន់ការពារធម្មជាតិដោយប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព(VI)។

**តំបន់ការពារធម្មជាតិ៖** អង្គការសហភាពអន្តរជាតិ ដើម្បីការអភិរក្សធម្មជាតិ កំណត់ទីតាំងភូមិសាស្ត្រ ដែលត្រូវទទួលស្គាល់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដើម្បីសម្រេចបាននូវការអភិរក្សធម្មជាតិយូរអង្វែង ផ្សារភ្ជាប់នឹងសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងតម្លៃវប្បធម៌ (និយមន័យរបស់អង្គការ IUCN ឆ្នាំ២០០៨ )។

ចំណាត់ថ្នាក់ប្រភេទតំបន់ការពារធម្មជាតិ ដោយអង្គការ IUCN រួមមាន៖

ចំណាត់ថ្នាក់ប្រភេទតំបន់ (Ia)-តំបន់ធម្មជាតិបម្រុងទុកតឹងរឹង៖ វាជាតំបន់មួយ ដែលត្រូវបានការពារទាំងអស់ ប៉ុន្តែមានការប្រើប្រាស់ដោយមនុស្សតិចតួច ដើម្បីថែរក្សាលក្ខណៈភូមិសាស្ត្រ និងមនុស្សសាស្ត្រ នៃតំបន់ និងជីវៈចម្រុះ។ តំបន់ទាំងនេះ ជាជម្រកដែលជាមូលដ្ឋានគ្រឹះទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ីពីដើមកំណើត ដែលត្រូវបានការពារតឹងរឹង ពីការរំខានមនុស្ស លើកលែងការងារសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ការងារត្រួតពិនិត្យបរិស្ថាន និងការងារអប់រំដោយសារតែតំបន់ទាំងនេះ ត្រូវបានការពារតឹងរឹង វាផ្តល់បរិស្ថានដ៏ឧដុង្គឧត្តមតាំងពីយូរយាណាស់មកហើយ ដែលឥទ្ធិពលរបស់មនុស្សពីខាងក្រៅអាចបានវាស់វែង។

ចំណាត់ថ្នាក់ប្រភេទតំបន់ (Ib)-តំបន់ទីរហោឋាន៖ មានភាពដូចគ្នាទៅនឹងតំបន់បំរុងធម្មជាតិតឹងរឹង ប៉ុន្តែជាទូទៅត្រូវបានពង្រីកធំទៅៗ និងត្រូវបានការពារតិចតួច។ តំបន់ទាំងនេះ ជាតំបន់ការពារសម្បត្តិធម្មជាតិ ដែលមានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី (រួមទាំងការវិវត្តន៍ជាលំដាប់) ត្រូវបានទុកឱ្យលូតលាស់តាមធម្មជាតិ ឬធ្វើការពិសោធន៍ស្តារឡើងវិញ ករណីត្រូវបានរំខានពីសកម្មភាពមនុស្ស។ ទាំងនេះជាតំបន់ទ្រនាប់ដែលទប់ទល់នឹងឥទ្ធិពល នៃការប្រែប្រួលអាកាសធាតុ ការពារប្រភេទសត្វ ឬរុក្ខជាតិទទួលការគំរាមកំហែង និងការពារប្រព័ន្ធអេកូឡូស៊ី។

ចំណាត់ថ្នាក់ប្រភេទតំបន់ (II)-ឧទ្យានជាតិ៖ ជាតំបន់គ្របដណ្តប់ដោយគម្របព្រៃ និងមានគោលបំណងការពារប្រព័ន្ធអេកូឡូស៊ី។ ទោះជាយ៉ាងណា ឧទ្យានជាតិត្រូវតែថែរក្សាដោយមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការកសាងហេដ្ឋារចនាសម្ព័ន្ធ។ ឧទ្យានជាតិ ត្រូវបានគ្រប់គ្រង ដោយមានគោលការណ៍អនុញ្ញាតឱ្យមានការចូលរួមគាំទ្រសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការលើកកម្ពស់ការអប់រំ និងទេសចរណ៍កំសាន្តក្នុងកម្រិតមួយដែលនឹងបង្កើននូវប្រសិទ្ធភាពនៃកិច្ចប្រឹងប្រែងអភិរក្ស។

ចំណាត់ថ្នាក់ប្រភេទតំបន់ (III)-បូជនីយដ្ឋាន ឬលក្ខណៈធម្មជាតិ៖ ជាកេរដំណែលមរតកប្រវត្តិសាស្ត្រ ឬលក្ខណៈធម្មជាតិ ដែលត្រូវបានបម្រុងទុកជាពិសេស ដើម្បីការពារកេរមត៌កទុកឱ្យកូនចៅជំនាន់ក្រោយ។ តំបន់នេះ គប្បីការពារជីវចម្រុះ ឬម្យ៉ាងវិញទៀត ត្រូវចាត់ថ្នាក់ជាតំបន់ប្រវត្តិសាស្ត្រ ឬតំបន់ខាងផ្លូវស្មារតី ដែលត្រូវការស្រាវជ្រាវយ៉ាងល្អិតល្អន់បំផុត។

ចំណាត់ថ្នាក់ប្រភេទតំបន់ (IV)-តំបន់គ្រប់គ្រងទីជម្រក ឬបន្តពូជ៖ មានលក្ខណៈជាកេរដំណែលធម្មជាតិ ដែលផ្តោតទៅលើតំបន់ដែលត្រូវការពារ និងអភិរក្សជាក់លាក់បំផុត។ តំបន់ការពារធម្មជាតិនេះ នឹងត្រូវការការពារដោយប្រុងប្រយ័ត្ន ដើម្បីជានាការថែរក្សា ការអភិរក្ស និងការស្តារឡើងវិញនៃប្រភេទ និងទីជម្រកសំខាន់ៗ។

ចំណាត់ថ្នាក់ប្រភេទតំបន់ (V)-តំបន់ការពារទេសភាព/លំហរសមុទ្រ៖ គ្របដណ្តប់ទូទាំងផ្ទៃដី ឬមហាសាគរ ដែលត្រូវមានផែនការអភិរក្សធម្មជាតិដោយជាក់លាក់ ជាទូទៅត្រូវផ្សារភ្ជាប់ទៅនឹងសកម្មភាពផលប្រយោជន៍ផងដែរ។ គោលបំណងចំបងៗ គឺដើម្បីការពារតំបន់នេះឱ្យប្រសើរឡើងនូវប្រព័ន្ធអេកូឡូស៊ីខុសៗគ្នា ដែលមានតម្លៃជីវៈចម្រុះ និងលក្ខណៈវប្បធម៌ ឬទស្សនីយភាពធម្មជាតិ។ ផ្ទុយមកវិញ នៅក្នុងប្រភេទចំណាត់ថ្នាក់មុនៗ ចំណាត់ថ្នាក់នេះ អនុញ្ញាតឱ្យសហគមន៍នៅជុំវិញធ្វើសកម្មភាពនៅក្នុងតំបន់នេះ ដើម្បីចូលរួមគ្រប់គ្រងធម្មជាតិ និងកេរមរតកវប្បធម៌ដោយនិរន្តរភាព។

ចំណាត់ថ្នាក់ប្រភេទតំបន់ (VI)-តំបន់ការពារធម្មជាតិដោយប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព៖ តាមរយៈអំពើរបស់មនុស្ស គឺជាកត្តាសំខាន់ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិទាំងនេះ។ មិនត្រូវឱ្យមានការអនុញ្ញាតការអភិវឌ្ឍឧស្សាហកម្មផលិតកម្មខ្នាតធំ ឬការអភិវឌ្ឍដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ។ អភិបាលកិច្ច ត្រូវរៀបចំ ឱ្យសមស្របនឹងតំបន់ការពារធម្មជាតិផ្សេងៗគ្នា និងអាចបង្កើនលទ្ធភាពទាញយកផលពីធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**ភាគីពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ៖** ភាគីពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ គឺជាភាគី ក្រសួង ស្ថានប័នមានសមត្ថកិច្ច អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច វិស័យឯកជន។ល។ដែលបានចូលរួមក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

**ភាគីពាក់ព័ន្ធនឹងការកំណត់បែងចែកតំបន់គ្រប់គ្រង៖** ភាគីដែលត្រូវចូលរួមធ្វើការកំណត់បែងចែកតំបន់គ្រប់គ្រង។

**របៀងជីវៈចម្រុះ៖** ជាតំបន់តភ្ជាប់តំបន់ការពារធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានជាអាទិ៍តំបន់ឧទ្យានជាតិ តំបន់ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់បេតិកភណ្ឌធម្មជាតិ តំបន់ស្នូលឋបនីយជីវមណ្ឌល និងតំបន់ឧទ្យានសមុទ្រ ដើម្បីទ្រទ្រង់សារព័ន្ធមជ្ឈដ្ឋានធម្មជាតិនៃតំបន់ប្រព័ន្ធអេកូឡូស៊ី។

**ការតភ្ជាប់ជម្រកសត្វ៖** ជាតំបន់ទេសភាពអាចជួយសម្រួលដល់ការធ្វើចលនាបន្លាស់ទីរបស់សត្វ និងលំហូរអេកូឡូស៊ី។ ការតភ្ជាប់ជម្រកសត្វ ត្រូវបានចាត់ទុកជាកត្តាមួយដ៏សំខាន់ក្នុងចំណោមកត្តាសំខាន់ជាច្រើន ដើម្បីថែរក្សានូវជីវៈចម្រុះ សត្វព្រៃ និងរុក្ខជាតិ។ ការរក្សានូវលំហូរហ្សែន គឺមានសារៈសំខាន់សម្រាប់ទទួលបានហ្សែនល្អ និងអាចបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។

**ជម្រកសមស្រប៖** តំបន់សក្តានុពលទីជម្រកជីវសាស្ត្រទ្រទ្រង់ប្រភេទជីវៈចម្រុះ។ ទាំងនេះត្រូវបានចាត់ទុកជាមូលដ្ឋានតំបន់ចាំបាច់ដែលពុំអាចខ្វះបាន ដែលត្រូវការគាំពារកម្រិតខ្ពស់ដល់តម្រូវការប្រើប្រាស់ជាតំបន់ទីជម្រក និងតំបន់បង្កាត់ពូជ។

**ជីវៈចម្រុះ៖** គឺជាភាពផ្សេងៗគ្នាក្នុងចំណោមសារពាង្គកាយមានជីវិតដែលបានមកពីគ្រប់ប្រភពទាំងអស់ រួមមានទាំងលើដីគោក សមុទ្រ និងប្រព័ន្ធអេកូឡូស៊ីក្នុងទឹកផ្សេងៗទៀត និងក្នុងអេកូឡូស៊ីចម្រុះដែលវាជាផ្នែកមួយរួមបញ្ចូលទាំងជីវៈចម្រុះនៅក្នុងប្រភេទ រវាងប្រភេទសត្វ រុក្ខជាតិនានា និងប្រព័ន្ធអេកូឡូស៊ី។

**មុខងារអេកូឡូស៊ី៖** គឺសំដៅអន្តរអំពើការរស់ជាមួយមជ្ឈដ្ឋានធម្មជាតិ (មានជីវិត និងគ្មានជីវិត)។

**សេវាកម្មប្រព័ន្ធអេកូឡូស៊ី៖** អាចត្រូវបានកំណត់ទៅតាមវិធីផ្សេងៗគ្នា។ ការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីសហសវត្សរ៍ បានចាត់ថ្នាក់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដូចជា ១)សេវាកម្មគ្រាំទ្រ៖ សេវាកម្មដែលចាំបាច់សម្រាប់ផលិតផលរបស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីរួមមាន ការបំលែងដី ការធ្វើរស្មីសំយោគ ផលិតផលបឋម វដ្តសារធាតុចិញ្ចឹម និងវដ្តទឹក ២)សេវាកម្មផ្គត់ផ្គង់៖ ផលិតផលដែលបានមកពីប្រព័ន្ធអេកូឡូស៊ី រួមមានប្រភពអាហារជាតិសរសៃ ប្រេង ប្រភពហ្សែន គីមីជីវៈ ឱសថធម្មជាតិ សមាសភាពផ្សំសម្រាប់ធ្វើឱសថ រុក្ខជាតិលម្អ និងទឹកស្អាត ៣)សេវាកម្មនិយ័តកម្ម៖ ផលប្រយោជន៍ទទួលបានពីនិយ័តកម្មដំណើរការរបស់អេកូឡូស៊ី ដូចជា និយ័តកម្មគុណភាពខ្យល់បរិសុទ្ធ អាកាសធាតុ ទឹក ការហូរច្រោះ ការបន្សុទ្ធទឹក ជម្ងឺ សត្វល្អិត ការពោយលំអងផ្កា និងនិយ័តកម្មគ្រោះធម្មជាតិ និង ៤)សេវាកម្មវប្បធម៌៖ អត្ថប្រយោជន៍ មិនមែនជាសម្ភារដែលមនុស្សទទួលបានពីប្រព័ន្ធអេកូឡូស៊ី តាមរយៈការផ្តល់មូលដ្ឋានខាងស្មារតី ចំណេះដឹង ការឆ្លុះបញ្ចាំង ការលំហែកំសាន្ត និងទទួលបទពិសោធន៍ខាងផ្នែកសោភណភាព ដែលទាំងនេះចាត់ទុកជាតម្លៃទេសភាព។

# សេចក្តីសង្ខេប

គោលបំណងនៃការកំណត់បែងចែកតំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ គឺដើម្បីកំណត់តំបន់គ្រប់គ្រងឱ្យត្រូវតាមមុខងារជីវៈចម្រុះ ភូមិសាស្ត្រ និងតម្រូវការសង្គម វប្បធម៌ សេដ្ឋកិច្ច ទាំងនេះជាយុទ្ធសាស្ត្រសម្រាប់ការការពារ អភិរក្ស និងប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព។

ការកំណត់ បែងចែកតំបន់គ្រប់គ្រង ត្រូវអនុវត្តឱ្យបាននូវការបញ្ចៀសទំនាស់នៃការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិ ធ្វើឱ្យមានសុក្រឹត្យភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងផ្តល់វិភាគទានជាអតិបរមាដល់ការកំណើនសេដ្ឋកិច្ចសង្គម-ជនបទ។

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ(ឆ្នាំ២០០៨) ផ្តល់នូវមូលដ្ឋានផ្លូវច្បាប់ សម្រាប់កំណត់បែងចែកតំបន់គ្រប់គ្រង ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ដើម្បីជានា៖ ប្រសិទ្ធភាពការគ្រប់គ្រងតំបន់នីមួយៗ និងការការពារពេញលេញនៃទីតាំងនានា ដែលផ្តល់តម្លៃខ្ពស់ដល់ការអភិរក្ស ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាពនៅតំបន់ដែលមានតម្លៃអេកូឡូស៊ីទាប ប៉ុន្តែមានតម្លៃសេដ្ឋកិច្ចខ្ពស់ និងរាប់បញ្ចូលទាំងការចូលរួម និងផលប្រយោជន៍សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

គោលបំណងនៃការគ្រប់គ្រងក្នុងតំបន់នីមួយៗ តម្រូវការចាំបាច់នូវការរៀបចំកំណត់គោលដៅការពារ អភិរក្សតំបន់នីមួយៗឱ្យបានច្បាស់លាស់។ ទោះបីជាយ៉ាងណាក៏ដោយ ការកំណត់បែងចែកតំបន់គ្រប់គ្រងនីមួយៗ ត្រូវកំណត់មុខងារតំបន់គ្រប់គ្រងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ព្រមទាំង មិនចាំបាច់កំណត់តំបន់គ្រប់គ្រងទាំងបួនប្រភេទនៅក្នុងតំបន់ការពារធម្មជាតិតែមួយទេ។ ដោយហេតុថា ការបែងចែកតំបន់ដែលមានទំហំតូចៗ មិនមានសក្តានុពលគ្រប់គ្រាន់ សម្រាប់គាំទ្រដល់គោលបំណងគ្រប់គ្រងតំបន់ទាំង៤។ អាទិភាពខ្ពស់សម្រាប់ការកំណត់បែងចែកតំបន់គ្រប់គ្រង គួរតែផ្តល់ជូនចំពោះតំបន់ការពារធម្មជាតិដែលមានទំហំធំ កំពុងប្រឈមខ្លាំងពីការអភិវឌ្ឍ និងការប្រមូលផលព្រៃឈើ។ ការកំណត់បែងចែកតំបន់គ្រប់គ្រង ត្រូវមានភាពសាមញ្ញ ងាយយល់ដោយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ ដោយអនុវត្តតាមជំហានសំខាន់ៗ រួមមាន ការបង្កើតក្រុមការងាររៀបចំកំណត់បែងចែកតំបន់គ្រប់គ្រង វិធីសាស្ត្រនៃការសិក្សា ការសិក្សាបឋម ការសិក្សានៅទីវាល និងបញ្ចប់សេចក្តីព្រាង សុំការអនុម័ត។

## ១. សេចក្តីផ្តើម

### ១.១. សារតា នៃការរៀបចំគោលការណ៍ណែនាំស្តីពី ការកំណត់បែងចែកតំបន់គ្រប់គ្រង

គោលបំណងនៃឯកសារនេះ គឺផ្តល់នូវគោលការណ៍ណែនាំបច្ចេកទេស សម្រាប់កំណត់តំបន់គ្រប់គ្រងទាំង៤ ដូចមានចែងក្នុងមាត្រា១១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

គោលការណ៍ណែនាំដែលបានរៀបចំឡើង ដោយបង្កើតក្រុមការងាររៀបចំសេចក្តីព្រាង ប្រជុំពិនិត្យកែសម្រួលផ្ទៃក្នុង ដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ កិច្ចប្រជុំពិគ្រោះយោបល់ផ្តល់ជាតុចូលពីអង្គការដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល សិក្ខាសាលាពីគ្រោះយោបល់ថ្នាក់ជាតិ អនុម័តដោយក្រសួងបរិស្ថាន និងចេញប្រកាសឱ្យប្រើដោយក្រសួងបរិស្ថាន។

គោលការណ៍ណែនាំដែលបានរៀបចំឡើងនេះ បានកំណត់លក្ខណៈវិនិច្ឆ័យ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ សេដ្ឋកិច្ច សង្គម វប្បធម៌ ស្ថានភាពភូមិសាស្ត្រ និងកិច្ចពិគ្រោះយោបល់អ្នកពាក់ព័ន្ធ។

### ១.២. ប្រព័ន្ធតំបន់ការពារធម្មជាតិ

ប្រទេសកម្ពុជា ជាប្រទេសដែលសម្បូរទៅដោយជីវៈចម្រុះ និងមានប្រភេទរុក្ខជាតិ សត្វ ជិតពូជ ឬមានដោយកម្រនៅក្នុងពិភពលោក។ សន្ទស្សន៍ជីវៈចម្រុះ (Biodiversity Index) ក្នុងប្រទេសកម្ពុជា គឺទទួលបានពិន្ទុ៧.៥ (MacKinnon, ១៩៩៧) ទោះបីជាយ៉ាងណាក៏ដោយ ពិន្ទុអាចបានខ្ពស់ជាងនេះ អាស្រ័យទៅលើការសិក្សាស្រាវជ្រាវ។ ប្រទេសកម្ពុជា ជាប្រទេសសម្បូរទៅដោយជីវៈចម្រុះដែលបានបង្ហាញវត្តមានប្រភេទថនិកសត្វ១២៣ប្រភេទ សត្វស្លាប៥៤៥ប្រភេទ ឧរង្គសត្វ៨៨ប្រភេទ រុក្ខជាតិតូចៗ (vascular plants) ២៣០៨ប្រភេទ ត្រី៨៧៤ប្រភេទ ផ្កាថ្មរឹង២៤ប្រភេទ ផ្កាថ្មទន់១៤ប្រភេទ ស្មៅសមុទ្រ១០ប្រភេទ និងថលជលិក៦៣ប្រភេទ។ នៅមានវត្តមានប្រភេទរុក្ខជាតិ និងសត្វមួយចំនួនទៀត ដែលមិនទាន់សិក្សាស្រាវជ្រាវ និងកំណត់អត្តសញ្ញាណនៅឡើយ។ មានប្រភេទរុក្ខជាតិ និងសត្វដែលបានកំណត់ក្នុងបញ្ជីក្រហមរបស់អង្គការសហភាពអន្តរជាតិ ដើម្បីការអភិរក្សធម្មជាតិ (IUCN) ក្នុងតារាង១ ដូចជា៖ ថនិកសត្វ៣៩ប្រភេទ សត្វស្លាប៣៦ប្រភេទ ឧរង្គសត្វ១៣ប្រភេទ រុក្ខជាតិតូចៗ (vascular plants) ៣៨ប្រភេទ និង ថលជលិក១២ប្រភេទ ។

តារាង១ ៖ ស្ថានភាពបច្ចុប្បន្ន នៃប្រភេទរុក្ខជាតិ និងសត្វដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា

| ប្រភេទ | ចំនួនសរុប នៃប្រភេទបានទទួលស្គាល់ | ក្នុងបញ្ជីក្រហមរបស់អង្គការ IUCN |
|---|---|---|
| ថនិកកសត្វ | ១២៣ | ៣៩ |
| សត្វស្លាប | ៥៤៥ | ៣៦ |
| ឧរង្គសត្វ | ៨៨ | ១៣ |
| រុក្ខជាតិតូចៗ | ២៣០៨ | ៣៨ |
| ត្រី | ៨៧៤ | - |
| ផ្ការថ្មរឹង | ២៤ | - |
| ផ្ការថ្មទន់ | ១៤ | - |
| ស្មៅសមុទ្រ | ១០ | - |
| ថលជលិក | ៦៣ | ១២ |

ប្រភព៖ របាយការណ៍ជាតិលើកទី៤ ដាក់ជូនអនុសញ្ញាស្តីពីជីវៈចម្រុះ ក្រសួងបរិស្ថាន ឆ្នាំ២០១០

ទិន្នន័យអំពីការបាត់បង់ធនធានព្រៃឈើ នៅមានកម្រិតកំណត់ ប៉ុន្តែទិន្នន័យក្នុងឯកសារគម្របព្រៃឈើកម្ពុជាឆ្នាំ២០១៤ បានបង្ហាញពីការថយចុះពី ៦១% ឆ្នាំ២០០២ មក៤៦,៩% ឆ្នាំ២០១៤។ ដើម្បីកាត់បន្ថយនៃការបាត់បង់ និងរិចរិលព្រៃឈើ និងជីវៈចម្រុះដ៏សំបូរបែប រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅក្នុងការការពារ និងអភិរក្សធនធានព្រៃឈើធម្មជាតិ។ ចាប់តាំងពីមានការហាមឃាត់ការកាប់ឈើក្នុងឆ្នាំ២០០២ និងបញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅឆ្នាំ២០១២ ផ្ទៃដីតំបន់ការពារធម្មជាតិបានកើនឡើងពី ៣,២លានហិកតា ដល់ប្រមាណ ៧,៥លានហិកតា ស្មើនឹង ៤១% នៃផ្ទៃដីទូទាំងប្រទេស។

ការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ព្រមជាមួយការរីកចម្រើនឆាប់រហ័សនៃការអភិវឌ្ឍសេដ្ឋកិច្ច ដែលចាំបាច់ត្រូវមានតុល្យភាពរវាងការអភិរក្សជីវៈចម្រុះ និងជីវភាពរស់នៅរបស់ប្រជាជននោះ គប្បីត្រូវការបង្កើតតំបន់គ្រប់គ្រងផ្សេងៗគ្នានៅក្នុងតំបន់ការពារធម្មជាតិ។

ច្បាប់ លិខិតបទដ្ឋាន គោលនយោបាយ និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិមានដូចជា៖

- ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិឆ្នាំ១៩៩៣
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ (កំណត់សូចនាករបង្កើនផ្ទៃដីគ្រប់គ្រងតំបន់ការពារធម្មជាតិ)
- ផែនការយុទ្ធសាស្ត្រ និងសកម្មភាពជាតិស្តីពីជីវៈចម្រុះឆ្នាំ២០១៥
- កម្មវិធីព្រៃឈើជាតិ២០១០-២០២៩
- ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ២០១៧-២០៣១
- យុទ្ធសាស្ត្ររេដបូកជាតិ២០១៨-២០២៨

តំបន់ការពារធម្មជាតិ មាន៨ប្រភេទ (តារាង២) ដូចដែលបានចែងក្នុងមាត្រា៧នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ និងចែកចេញជា៤តំបន់គ្រប់គ្រង គឺតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។

តំបន់ការពារធម្មជាតិលើកដំបូងនៅប្រទេសកម្ពុជា បានបង្កើតឡើងដោយប្រកាសឆ្នាំ១៩២៥ គឺឧទ្យានខាងបុរាណវត្ថុវិទ្យាអង្គរ ដែលជាឧទ្យានជាតិមុនគេបង្អស់នៅតំបន់អាស៊ីអាគ្នេយ៍។ ក្រោយបញ្ចប់សង្គ្រាមស៊ីវិលរាំរ៉ៃមក តំបន់ការពារធម្មជាតិត្រូវបានបង្កើតឡើងនៅ ឆ្នាំ១៩៩៣ និងបន្តរហូតដល់ខែវិច្ឆិកាឆ្នាំ២០១៧ មានចំនួន៥០តំបន់ និងរបៀងអភិរក្សជីវៈចម្រុះសម្រាប់តំបន់ការពារធម្មជាតិ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន។ ប្រមាណ ៣០% នៃផ្ទៃដីទូទាំងប្រទេស អាចចាត់ទុកថាជាតំបន់ដីសើម និងតំបន់ផ្សេងៗទៀត អាចបង្កើតនៅក្រោមអនុសញ្ញារ៉ាមសា នាពេលអនាគត។

តារាង២៖ ប្រព័ន្ធតំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជា

| ល.រ | ឈ្មោះតំបន់ | ចំនួន | មុខងារ | ចំណាត់ថ្នាក់ប្រភេទតំបន់ដោយIUCN |
|---|---|---|---|---|
| ១ | តំបន់ឧទ្យានជាតិ | ១២ | បំរើឱ្យវិទ្យាសាស្ត្រ អប់រំ និងកំសាន្ត | II |
| ២ | តំបន់ដែនជម្រកសត្វព្រៃ | ១៩ | ការពារ និងអភិរក្សរុក្ខជាតិ និងសត្វ | I |
| ៣ | តំបន់ការពារទេសភាព | ៩ | អភិរក្សទេសភាពធម្មជាតិ និងពាក់កណ្តាលធម្មជាតិ សម្រាប់រមណីយដ្ឋាន និងទេសចរណ៍ធម្មជាតិសម្រាប់សាធារណៈជន | III |
| ៤ | តំបន់ប្រើប្រាស់ច្រើនយ៉ាង | ៥ | ការពារ និងអភិរក្សជីវៈចម្រុះ និងផ្តល់ផលិតផល និងសេវាកម្មធម្មជាតិ | IV |
| ៥ | តំបន់ឋបនីយជីវមណ្ឌល | ១ (ក្នុងតំបន់រ៉ាមសារ) | តំបន់អភិរក្សជីវៈចម្រុះ និងប្រើប្រាស់ដោយនិរន្តរភាព | |
| ៦ | តំបន់បេតិកភណ្ឌធម្មជាតិ | ២ | ជាតំណាងប្រព័ន្ធធម្មជាតិតំបន់ធម្មជាតិ ឬសារៈសំខាន់សោភណភាព ឬវប្បធម៌ | III |
| ៧ | តំបន់ឧទ្យានជាតិសមុទ្រ | ១ | កោះគ្របដណ្តប់ព្រៃឈើ សត្វនិងមច្ឆជាតិ ដែលមានលក្ខណៈប្រវត្តិសាស្ត្រ និងតម្លៃវប្បធម៌។ | |
| ៨ | តំបន់រ៉ាមសារ | ៤ | សារៈសំខាន់នៃអេកូឡូស៊ី និងជីវៈចម្រុះ ដីសើមជាលក្ខណៈអន្តរជាតិ | |

## ១.៣. ការអនុវត្តអនុសញ្ញាអន្តរជាតិ

លេខាធិការដ្ឋានគ្រប់គ្រងបរិស្ថានដំបូង ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលនាឆ្នាំ១៩៩៣ និងបន្ទាប់មក ត្រូវបានបង្កើតក្រសួងបរិស្ថាននាឆ្នាំ១៩៩៦។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីជីវៈចម្រុះឆ្នាំ១៩៩៥ និងអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ១៩៩៥ អនុសញ្ញារ៉ាមសារឆ្នាំ១៩៩៦ អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទរុក្ខជាតិ និងសត្វព្រៃ ដែលកំពុងរងគ្រោះ និងជិតផុតពូជ(CITES) ឆ្នាំ១៩៩៧ អនុសញ្ញាបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៩១ និងកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍដោយចីរភាពនៃអាងទន្លេមេគង្គឆ្នាំ១៩៩៥។ ចំពោះការផ្តល់សច្ចាប័នទាំងនេះ ប្រទេសកម្ពុជាបានផ្សារភ្ជាប់នឹងសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ដែលយកចិត្តទុកដាក់លើការងារការការពារ និងអភិរក្សជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិ។ ដូចនេះ ការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ គឺជាជំហានដ៏សំខាន់ សម្រាប់ឆ្ពោះទៅរកការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយសុក្រឹតភាព ស្របនឹងការប្តេជ្ញាចិត្តជាអន្តរជាតិ។

### ១.៤. ក្របខណ្ឌច្បាប់ សម្រាប់ការកំណត់បែងចែកតំបន់គ្រប់គ្រង

យោងតាមការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ក្រសួងបរិស្ថានបានពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងតំបន់ការពារធម្មជាតិឱ្យមានលក្ខណៈជាប្រព័ន្ធ ដើម្បីធានាការពារ និងអភិរក្សធនធានធម្មជាតិ កម្ពុជាឱ្យស្ថិតស្ថេរចីរកាលតរៀងទៅ។ ហេតុដូច្នេះហើយ ផ្ទៃដីព្រៃឈើនៃតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ត្រូវបានពង្រីកវិសាលភាពឱ្យស្របនឹងតម្រូវការ នៃការអភិរក្សប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ ពីចំនួន៣,២លានហិកតា ដល់ប្រមាណ ៧,៥លានហិកតា ស្មើនឹង៤១% នៃផ្ទៃដីប្រទេសកម្ពុជាឆ្នាំ២០១៦។

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ជាឧបករណ៍គតិយុត្ត សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ការពារធម្មជាតិ ជាពិសេសបទប្បញ្ញត្តិឱ្យរៀបចំកំណត់បែងចែកតំបន់ការពារធម្មជាតិជា ៤តំបន់រួមមាន៖ តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។

ដើម្បីពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗ ឱ្យត្រូវតាមមុខងារ សេវា និងតម្លៃប្រព័ន្ធអេកូឡូស៊ី បំរើឱ្យការងារអភិរក្សបេតិកភណ្ឌធម្មជាតិ សេដ្ឋកិច្ច សង្គម និងបរិស្ថាន តម្រូវការចាំបាច់ត្រូវធ្វើការការកំណត់បែងចែងតំបន់គ្រប់គ្រងនៅក្នុងតំបន់ការពារធម្មជាតិ។ ដូចនេះ គោលការណ៍ណែនាំស្តីពីការកំណត់បែងចែងគ្រប់គ្រងតំបន់ការពារធម្មជាតិ ជាឧបករណ៍សម្រាប់ការអនុវត្តកំណត់បែងចែកតំបន់គ្រប់គ្រងនីមួយៗ ឱ្យស្របតាមគោលបំណងមុខងារនៃតំបន់ការពារធម្មជាតិ។

## ២. ចក្ខុវិស័យ

ការគ្រប់គ្រងតំបន់គ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវធានានិរន្តរភាពប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ បេតិកភ័ណ្ឌវប្បធម៌ធម្មជាតិ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដែលជាមូលដ្ឋានគ្រឹះសុខុមាលភាពសាធារណៈ។

## ៣. បេសកកម្ម

សុក្រឹត្យភាពការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ គោលនយោបាយជាតិ អនុសញ្ញាអន្តរជាតិ និងធ្វើឱ្យប្រសើរឡើងនូវការអភិរក្សជីវៈចម្រុះ មុខងារប្រព័ន្ធអេកូឡូស៊ី និងគុណភាពបំណិនជីវភាពរស់នៅប្រជាជនមូលដ្ឋាន។

## ៤. គោលបំណង

ផ្តល់វិភាគទានជាអតិបរមានូវប្រសិទ្ធភាពនៃការការពារ និងអភិរក្សជីវៈចម្រុះក្នុងតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ ដោយមានការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ។

## ៥. លក្ខណវិនិច្ឆ័យសម្រាប់កំណត់ បែងចែកតំបន់គ្រប់គ្រង

តំបន់ការពារធម្មជាតិត្រូវបានបង្កើតឡើង គឺធានានូវការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការធានាការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព។ ជាមួយគ្នានេះដែរ ការធ្វើឱ្យប្រសើរ

ឡើងនូវជីវភាពប្រជាជនរបស់សហគមន៍ដែលបានបង្កើតរួចហើយក៏ត្រូវយកមកគិតគូរ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ដែលមានលក្ខណវិនិច្ឆ័យអេកូឡូស៊ី ឬការយកចិត្តទុកដាក់ជាអាទិភាពខ្ពស់បំផុត។

មាត្រា១២ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ បានចែងនូវពីលក្ខណវិនិច្ឆ័យ ដើម្បីកំណត់បែងចែកតំបន់គ្រប់គ្រង រួមមាន៖ គោលបំណងនៃការគ្រប់គ្រងតំបន់ តម្លៃមានសក្តានុពលធនធានធម្មជាតិនៅក្នុងតំបន់នីមួយៗ សេដ្ឋកិច្ចសង្គម និងវប្បធម៌ លទ្ធភាពទ្រទ្រង់នៃធនធានធម្មជាតិ និងទីតាំងភូមិសាស្ត្រនៃតំបន់នីមួយៗ។

## ៥.១. គោលបំណងនៃការគ្រប់គ្រងតំបន់នីមួយៗ

### ៥.១.១. តំបន់ស្នូល

ត្រូវគ្រប់គ្រងសម្រេចឱ្យបាននូវទំហំដែនដីនៃប្រព័ន្ធអេកូឡូស៊ីដែលមានតម្លៃជាអតិបរមា សម្រាប់ការការពារដាច់ខាត រួមមានប្រភេទរុក្ខជាតិ សត្វ ដែលមានដោយកម្រ ជិតផុតពូជ ងាយរងគ្រោះគំរាមកំហែង ប្រព័ន្ធអេកូឡូស៊ីផុយស្រួយ និងធនធានធម្មជាតិ។

### ៥.១.២. តំបន់អភិរក្ស

ជាតំបន់ស្ថិតនៅជាប់តំបន់ស្នូលដែលត្រូវការពារ និងអភិរក្សប្រព័ន្ធអេកូឡូស៊ី និងសេវារបស់វាប្រភេទរុក្ខជាតិ សត្វ ធនធានធម្មជាតិ ទីជម្រាល និងតំបន់ដែលមានលក្ខណសោភណភាពទេសភាពធម្មជាតិ។ សហគមន៍មូលដ្ឋាន អាចបង្កើតប្រាក់ចំណូលពីសកម្មភាពអេកូទេសចរណ៍ ដោយមិនមានផលប៉ះពាល់ និងរំខាន ឬរំខានតិចតួចដល់រុក្ខជាតិ និងសត្វ។

### ៥.១.៣. តំបន់ប្រើប្រាស់ដោយចីរភាព

ត្រូវគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព ដើម្បីរួមចំណែកការពារ និងអភិរក្សតំបន់ការពារធម្មជាតិ អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរស់របស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។ ការអភិវឌ្ឍ ឬការប្រើប្រាស់ធនធានធម្មជាតិ ត្រូវធានានូវនិរន្តរភាពមុខងារ និងប្រព័ន្ធអេកូឡូស៊ី ដោយមិនអនុញ្ញាតឱ្យផ្លាស់ប្តូរគម្របធនធានព្រៃឈើ។

### ៥.១.៤. តំបន់សហគមន៍

ត្រូវគ្រប់គ្រង បំរើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលកំពុងមានសកម្មភាពស្រាប់ រួមមានដីលំនៅដ្ឋាន ស្រែ និងចំការ និងដីកសិកម្មពនេចរ។ ការគ្រប់គ្រងតំបន់នេះ ត្រូវអនុវត្តចំពោះប្រជាសហគមន៍មូលដ្ឋាន ឬជនជាតិដើមភាគតិចប៉ុណ្ណោះ និងសកម្មភាពក្រៅពីនេះ មិនស្ថិតនៅក្នុងកម្មវត្ថុនៃតំបន់សហគមន៍ឡើយ។ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ភូមិបាល។

## ៥.២. លក្ខណវិនិច្ឆ័យផ្នែកអេកូឡូស៊ី

លក្ខណវិនិច្ឆ័យផ្នែកអេកូឡូស៊ីសម្រាប់កំណត់បែងចែកតំបន់គ្រប់គ្រងមានចំនួន ៤លក្ខណវិនិច្ឆ័យ ដូចខាងក្រោម៖

### ៥.២.១. ទីតាំង ទំហំ និងទ្រង់ទ្រាយ

ចំនួនរុក្ខជាតិ សត្វ នៅក្នុងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិ ដែលមានហានិភ័យប្រឈមនឹងការផុតពូជ ប្រភេទបក្សីដែលជាប្រភេទមានដោយកម្រ និងជិតផុតពូជ ប្រភេទសត្វធ្វើទេសន្តរវេសន៍ អន្លង់ធំៗ និងជ្រោះដែលមានទីតាំងក្នុងតំបន់ដីសើម តំបន់ទឹកធ្លាក់ តំបន់ភ្នំ តំបន់ឆ្នេរ សមុទ្រ និងតំបន់បំរុងតភ្ជាប់ ឬតំបន់កោះ។ តំបន់ស្នូល ត្រូវតែមានទំហំធំល្មម និងមានរាងជារង្វង់ ឬក៏ស្រដៀងទៅនឹងរង្វង់តាមដែលអាចធ្វើទៅបាន។ ក្នុងករណីដែលមិនមានផ្ទៃដីធំ សម្រាប់កំណត់ជាតំបន់ស្នូលទេនោះ តំបន់ស្នូលតូចៗច្រើនកន្លែង អាចនឹងត្រូវបង្កើតឡើង ដើម្បីការពារប្រភេទរុក្ខជាតិ និងសត្វឱ្យបានសមស្របនឹងលក្ខខណ្ឌជីវៈសាស្ត្រ។

### ៥.២.២. ឥទ្ធិពលរបស់ជ្រុង (ជាយ) នៃតំបន់គ្រប់គ្រង

តំបន់គ្រប់គ្រង ជាពិសេសតំបន់ស្នូល និងតំបន់អភិរក្ស ចាំបាច់ត្រូវតែកំណត់ឥទ្ធិពលរបស់ជ្រុងនីមួយៗ ដើម្បីការពារការរាតត្បាតពីរុក្ខជាតិ សត្វក្រៅតំបន់ ឬសត្វរំពារ ឬហានិភ័យចំពោះការបរបាញ់ដោយមនុស្ស ក៏ដូចជាការផ្តល់នូវទំហំផ្ទៃដីគ្រប់គ្រាន់ សម្រាប់រុក្ខជាតិ សត្វដែលត្រូវការជម្រកខាងក្នុងសម្រាប់ការបន្តពូជនៅក្នុងតំបន់ស្នូល ឬតំបន់អភិរក្ស។

### ៥.២.៣. តំណភ្ជាប់

តំណភ្ជាប់ ឬការតភ្ជាប់ជម្រក មានសារៈសំខាន់ សម្រាប់ការធ្វើចលនាបន្លាស់ទីរបស់សត្វ និងធ្វើឱ្យមានលំហូរហ្សែន។ ការកំណត់តំបន់តំណភ្ជាប់ជាបំណែកៗ ជាបន្ទាត់ត្រង់ នឹងអាចធ្វើឡើងដោយយោងតាមស្ថានភាពនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឬការអភិវឌ្ឍផ្សេងៗទៀត ជាពិសេសក្នុងតំបន់ដែលទ្រទ្រង់ដល់តម្លៃនៃការអភិរក្សខ្ពស់ នៅក្នុង ឬឆ្លងកាត់តំបន់ការពារធម្មជាតិ ឬបៀងអភិរក្សជីវៈចម្រុះ និងតំបន់ឆ្នេរ សមុទ្រដែលត្រូវតភ្ជាប់ជាមួយដីគោក និងតំបន់ទីជម្រាល។

គ្រប់គម្រោងសំណើអភិវឌ្ឍន៍ នៅក្នុងតំបន់ការពារធម្មជាតិ ឬបៀងអភិរក្សជីវៈចម្រុះ ត្រូវសិក្សានិងវាយតម្លៃហេតុប៉ះពាល់បរិស្ថានមុននឹងចាប់ផ្តើមធ្វើការអភិវឌ្ឍ និងត្រូវអនុញ្ញាតដោយក្រសួងបរិស្ថាន។ ត្រូវដាក់ស្លាកសញ្ញាសម្គាល់តំបន់សត្វឆ្លងកាត់ តំបន់ហាមឃាត់ការតាំងទីលំនៅ តំបន់បន្ថយល្បឿន តំបន់មិនមានសំលេងរំខាន និងតំបន់គ្មានសំណល់រឹង និងរាវ។...ល។

### ៥.២.៤. ជម្រកសមស្រប

សត្វព្រៃប្រភេទធំៗដូចជាដំរី ត្រូវបានគំរាមកំហែងដោយការបាត់បង់ជម្រក។ ដំរីអាស៊ីត្រូវការផ្ទៃដីយ៉ាងហោចណាស់ពី១៥ ទៅ៥០គម² ឬពី៥០០ ទៅ៨០០គម²។ ស្រដៀងគ្នានេះដែរ ខ្លាដំបងញី

ត្រូវការផ្ទៃដីទំហំពី១៣ ទៅ៥១គម² ខណៈដែលខ្លាដំបងឈ្មោល ត្រូវការទំហំដីពី៦០ ទៅ១០០គម²។ ម្យ៉ាងវិញទៀតសត្វផ្សេង ត្រូវការទំហំផ្ទៃទឹកធំ ឬសមុទ្រធំវែង និងទឹកមានគុណភាពល្អ។

ជម្រកសមស្រប ត្រូវចាត់ទុកជាកត្តាដ៏សំខាន់ ក្នុងការកំណត់ទំហំតំបន់ស្នូល នៅក្នុងតំបន់ការពារធម្មជាតិ។ តំបន់ដីសើមដែលជាជម្រក សម្រាប់មច្ឆជាតិមានដោយកម្រ ជិតផុតពូជ វាលស្មៅដីប្រាប និងតំបន់ទ្រទ្រង់ជីវសាស្ត្ររុក្ខជាតិ សត្វដែលមានសក្តានុពលជីវៈចម្រុះគ្រប់ប្រភេទ។ តំបន់ទ្រទ្រង់ប្រភេទសត្វធ្វើការបន្លាស់ទីពីតំបន់មួយទៅតំបន់មួយទៀត។

## ៥.៣. លក្ខណវិនិច្ឆ័យសេដ្ឋកិច្ច-សង្គម

លក្ខណវិនិច្ឆ័យនេះ សំដៅទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដែលរស់នៅក្នុងតំបន់។ ការកំណត់បែងចែកតំបន់គ្រប់គ្រង ត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់ប្រជាពលរដ្ឋមូលដ្ឋាន សម្រាប់គោលបំណងទំនៀមទំលាប់ ជំនឿសាសនា និងការរស់នៅ និងត្រូវទទួលស្គាល់តំបន់វប្បធម៌ និងវប្បធម៌ធម្មជាតិសំខាន់ៗ (ឧទាហរណ៍ ព្រៃអារក្ស និងផ្នូរ ប្រាសាទ ល្អាងថ្ម)។

ក្នុងកិច្ចដំណើរការកំណត់ បែងចែកតំបន់គ្រប់គ្រង ត្រូវមានកិច្ចពិភាក្សាពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ដែលរស់នៅជិត ឬក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ។

## ៥.៤. លទ្ធភាពទ្រទ្រង់នៃធនធានធម្មជាតិ

គោលបំណងនៃការគ្រប់គ្រងតំបន់នីមួយៗឱ្យមានប្រសិទ្ធភាព ត្រូវគិតគូរ ពិចារណា ពីទីតាំង និងទំហំនៃតំបន់នីមួយៗ ក្នុងលក្ខខណ្ឌ និងលទ្ធភាពនៃធនធានធម្មជាតិបច្ចុប្បន្ន។

## ៥.៥.លក្ខណៈភូមិសាស្ត្រនៃតំបន់នីមួយៗ

លក្ខណៈភូមិសាស្ត្រនៃតំបន់នីមួយៗ ត្រូវគិតគូរ ពីមុខងារបឋមនៃប្រព័ន្ធអេកូឡូស៊ី រួមទាំងប្រភពធនធានទឹក (ទីជម្រាល ផ្ទៃរងអាងទឹកភ្លៀង និងផ្លូវទឹកផ្សេងៗទៀត) ប្រភេទដី និងដីដាំដំណាំកសិកម្ម។

ការសិក្សាលក្ខណៈភូមិសាស្ត្រទៅលើតំបន់គ្រប់គ្រងនីមួយៗមានជាអាទិ៍ ជម្រកសំខាន់ៗ សម្រាប់រុក្ខជាតិ សត្វ(បក្សី ថនិកសត្វ ឧរង្គសត្វ និងមច្ឆជាតិ)។

នៅក្នុងតំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ផ្លូវទឹកក៏អាចជាលក្ខណៈភូមិសាស្ត្រសមស្រប សម្រាប់សកម្មភាពទេសចរណ៍។ ដូចនេះហើយ ការកំណត់បែងចែកតំបន់គ្រប់គ្រង ត្រូវតែធានាឱ្យបាននូវការការពារប្រភពទឹក ដោយរួមបញ្ចូលទាំង ទីជម្រាល ផ្ទៃអាងរងទឹកភ្លៀង ប្រព័ន្ធផ្លូវទឹក បឹង ទន្លេ និងទម្រង់ផ្សេងទៀតនៃប្រភពធនធានទឹកដែលហូរចូលទៅក្នុងតំបន់គ្រប់គ្រងនីមួយៗ។ លើលក្ខណៈសណ្ឋានដី អាចប៉ះពាល់ទៅដល់ការកំណត់តំបន់គ្រប់គ្រងទាំងបួន ឧទាហរណ៍ តំបន់ដែលមានចំណោតខ្លាំង (៣៥ដឺក្រេ ឬខ្ពស់ជាងនេះ) គឺងាយរងគ្រោះ ពីការហូរច្រោះ ឬការរអិលបាក់ដី។ ស្ថានភាពលក្ខណៈភូមិសាស្ត្រនៃតំបន់បែបនេះ អាចកំណត់ជាតំបន់ស្នូល ឬតំបន់អភិរក្ស ដោយមានកិច្ចពិភាក្សារវាងភាគីពាក់ព័ន្ធ។

នៅតំបន់ព្រៃរេចរិល ដែលអាចដាំដុះស្តារព្រៃឡើងវិញ អាចកំណត់ជាតំបន់អភិរក្ស។

លក្ខណៈភូមិសាស្ត្រនៃតំបន់សំខាន់ៗ មិនត្រឹមតែជួរភ្នំក្រវាញ ដែលមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំខ្ពស់បំផុត (៣៥០០-៤០០០មល ក្នុង១ឆ្នាំ) និងជាទីជម្រាលចំណោតខ្ពស់បុណ្ណោះទេ នៅដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ដែនជម្រកសត្វព្រៃព្រៃឡង់ ដែនជម្រកសត្វព្រៃបឹងពែរ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» តំបន់ដែនជម្រកសត្វព្រៃបន្ទាយឆ្មារ តំបន់ការពារទេសភាពព្រះវិហារមានបណ្តាញប្រព័ន្ធផ្លូវទឹក (មានស្ទឹងសំខាន់ៗ ចំនួន១៤) និងប្រភពផ្គត់ផ្គង់ទឹកហូរចូលទៅក្នុងបឹងទន្លេសាប។

## ៦. ការកំណត់តំបន់គ្រប់គ្រងនីមួយៗ

គោលការណ៍ណែនាំនេះ ជាឧបករណ៍កំណត់បែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ដោយមានការកំណត់ទីតាំង ទំហំ និងធ្វើផែនទី។

### ៦.១. តំបន់ស្នូល

តំបន់ស្នូល ត្រូវកំណត់ដោយយោងតាមលក្ខណវិនិច្ឆ័យផ្នែកអេកូឡូស៊ី សម្រាប់សិក្សាកំណត់ទំហំ ទ្រង់ទ្រាយ និងតំណភ្ជាប់ទៅក្នុងតំបន់ផ្សេងៗទៀត។

តំបន់ស្នូល ត្រូវមានបណ្តុំនៃតម្លៃជីវៈចម្រុះសំខាន់ៗ សម្រាប់ ជាតិ តំបន់ ឬសកល។ លក្ខណវិនិច្ឆ័យដំបូង ត្រូវយកមកសិក្សារួមមាន៖

- វត្តមានចំណាត់ថ្នាក់ ប្រភេទរុក្ខជាតិ សត្វ ដែលមានដោយកម្រ ជិតផុតពូជ ងាយរងគ្រោះថ្នាក់ គំរាមកំហែង សម្រាប់ជាតិ តំបន់ ឬសកល
- ទីជម្រកសមស្រប ឬតម្រូវទំហំដែនដី សម្រាប់ប្រភេទរុក្ខជាតិ សត្វដែលមានដោយកម្រ ជិតផុតពូជ ងាយរងគ្រោះថ្នាក់ គំរាមកំហែង
- តំបន់មានសារៈសំខាន់របស់ជាតិ (បេតិកភណ្ឌវប្បធម៌ ឬបេតិកភណ្ឌធម្មជាតិ) និងប្រព័ន្ធអេកូឡូស៊ី ដែលងាយរងការខូចខាត ឬបាត់បង់
- មុខងារទីជម្រាល
- ទំនាក់ទំនងតភ្ជាប់ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ និងរបៀងជីវៈចម្រុះ។

ទំហំនៃតំបន់ស្នូល ត្រូវកំណត់ដោយលក្ខខណ្ឌ ជម្រកសមស្រប ឬតម្រូវការទំហំដែនដី និងលក្ខណវិនិច្ឆ័យពីទី១ ដល់ទី៥ ដូចមានចែងខាងលើ។ ទោះបីក្នុងទីតាំងទាំងនោះ មិនមានវត្តមានប្រភេទរុក្ខជាតិសត្វមានដោយកម្រ ជិតផុតពូជ ងាយរងគ្រោះថ្នាក់ និងគំរាមកំហែងក្តី ក៏ត្រូវពិចារណាសិក្សាទៅលើគម្របព្រៃទទួលរងរបបទឹកភ្លៀង នៅក្នុងផ្ទៃដីធនធានព្រៃឈើទាំងមូល ដោយមិនអាចបំបែកជាតំបន់តូចៗបានឡើយ។ ពីព្រោះ អាចធ្វើឱ្យបាត់បង់បរិមាណទឹកភ្លៀង គុណភាព និងប្រភពទឹកក្រោមដី។ ទំហំតំបន់ស្នូលនៃតំបន់ការពារធម្មជាតិ ដែលបានសិក្សារកឃើញទីតាំងប្រភពទឹកសាប និងតំបន់ឆ្នេរត្រូវកំណត់ទំហំដោយយោងតាមលក្ខខណ្ឌជម្រកសមស្រប ឬតម្រូវការទំហំដែនដី សម្រាប់ប្រភេទរុក្ខជាតិសត្វរងការគំរាមកំហែង។ ទាំងនេះ ព្រោះតែតម្លៃនៃជីវចម្រុះខ្ពស់ និងការគិតគូរខ្ពស់ទៅលើរបបចំណីអាហារ

រួមបញ្ចូលទាំងតំបន់ដីសើម ត្រូវបានចាត់ជាតំបន់ស្នូល ប្រសិនតំបន់ទាំងនេះ មិនមានប្រជាជនរស់នៅ។ បើមិនដូច្នោះទេ តំបន់នេះ ត្រូវចាត់ទុកជាតំបន់ស្នូល ដោយពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។

### ៦.១.១. តម្រូវការប្រវែងចម្ងាយ ឬទំហំសម្រាប់ជម្រកសមស្រប

ប្រវែងទំហំសម្រាប់ជម្រកសមស្របនៃប្រភេទសត្វធំៗ ត្រូវប្រើប្រាស់ជាសូចនាករ។ ឧទាហរណ៍ តម្រូវការទំហំ សម្រាប់ជម្រកដំរីអាស៊ី តម្រូវការទំហំពី ៥០គម² ទៅ៨០០គម² និងសម្រាប់តម្រូវការ សត្វខ្លាដំបងញីគឺទំហំ ១៣-១៥គម² និងសម្រាប់សត្វខ្លាដំបងឈ្មោល គឺ៣៣គម²-១៥១គម² ទីជម្រក និងទំហំដែនដី (Sunquist ១៩៨១, Smith et al. ១៩៨៩)។

តម្រូវការទំហំនៃជម្រកសមស្រប សម្រាប់ប្រភេទមួយចំនួន ដូចមានជូនភ្ជាប់នៅក្នុងឧបសម្ព័ន្ធ២។ ចំពោះទិន្នន័យនៃតម្រូវការជម្រកសមស្របដែលមិនមាន តំបន់បៃតងធម្មជាតិ (ឧទាហរណ៍ ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ឬព្រៃល្បោះ) ឬតំបន់ដែលស្ថិតនៅក្រោមការអនុវត្តគម្រោង រេដបូក (REED+ ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរិលព្រៃឈើ) អាចបម្រុងទុកជាតំបន់ស្នូល ប៉ុន្តែត្រូវពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។

ការកំណត់តំបន់ស្នូលនៅក្នុងតំបន់ឧទ្យានជាតិសមុទ្រ តំបន់ការពារធម្មជាតិនៅតាមបណ្តោយ តំបន់មាត់សមុទ្រ និងនៅក្នុងតំបន់ការពារធម្មជាតិដីសើម តម្រូវការចំណេះដឹងបន្ថែមស្តីពីសមុទ្រ និងឬ តម្រូវការជម្រកប្រភេទសត្វទឹកសាប និងវដ្តនៃជីវិតប្រចាំឆ្នាំ។

តំបន់ដីសើមនៅក្រោមអនុញ្ញារ៉ាមសារ អាចមានតំបន់ស្នូលធំៗ ឬអាចមានតំបន់ស្នូលតែមួយ រួមគ្នា តាមតម្រូវការចាំបាច់។ កិច្ចពិគ្រោះយោបល់ជាមួយអាជ្ញាធរពាក់ព័ន្ធ និង/ឬអ្នកជំនាញឯកទេសមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ជាតម្រូវការចាំបាច់ ដើម្បីជានាការការពារប្រភេទសត្វរងការគំរាមកំហែងជាសកល។

ទ្រង់ទ្រាយទម្រង់តំបន់ ត្រូវគិតគូរផងដែរទៅលើកត្តាឋានលេខា និងភូមិសាស្ត្រ ដើម្បីសម្រួលទៅលើការងារគ្រប់គ្រង និងអភិរក្សដែលមានលក្ខណៈជីវៈចម្រុះ និងប្រភេទសំខាន់។

ទំហំនៃតំបន់ស្នូល ត្រូវគិតគូរទៅលើគ្រប់ប្រភេទងាយរងគ្រោះថ្នាក់ជាសកល (សត្វស្លាប ល្មូន មច្ឆាជាតិ រុក្ខជាតិ)។

ដើម្បីរក្សាការពារប្រភេទសត្វបន្លាស់ទី និងលំហូរសេនេទិច តំបន់តំណភ្ជាប់ ត្រូវបង្កើតឡើងនៅចន្លោះ រវាងតំបន់ការពារធម្មជាតិនៅជិតគ្នា និងមិនត្រូវអនុញ្ញាតឱ្យតាំងទីលំនៅ នៅក្នុងតំបន់ជម្រកតំណភ្ជាប់គ្នា។

## ៦.២ តំបន់អភិរក្ស

តំបន់អភិរក្សមានតម្លៃអេកូឡូស៊ីខ្ពស់ លក្ខណវិនិច្ឆ័យអេកូឡូស៊ី ត្រូវបានផ្តល់តម្លៃអាទិភាពខ្ពស់ បន្ទាប់ពីតំបន់ស្នូល។ ទីតាំង និងទំហំតំបន់អភិរក្ស ត្រូវកំណត់ស្របតាមវត្តមានប្រភេទរងការគំរាមកំហែង ជាសកល និងការបន្លាស់ទី ប្រព័ន្ធអេកូឡូស៊ី ព្រមទាំងលក្ខណៈពិសេសរបស់ជម្រក លក្ខណៈភូមិសាស្ត្រ

(ឧទាហរណ៍ តំបន់ទីជម្រាលចោតខ្លាំង ៣៥ដឺក្រេ ឬតំបន់បរិស្ថានងាយរងគ្រោះថ្នាក់) និងតម្រូវការការពារតំបន់ទីជម្រាល តំបន់ផ្ទៃរងទឹកភ្លៀង និងប្រព័ន្ធផ្លូវទឹក។

ការអភិរក្សនៃទីជម្រាល ឬតំបន់ផ្ទៃរងទឹកភ្លៀង (រួមទាំងតំបន់ទឹកធ្លាក់) ត្រូវយកចិត្តទុកដាក់ជាបឋម កំណត់ជាតំបន់អភិរក្ស។ ទោះបីជាយ៉ាងណាក៏ដោយ អាស្រ័យលើការវាយតម្លៃ និងការព្រមព្រៀងបញ្ជាក់ថា មិនមានផលប៉ះពាល់អ្វី គួរឱ្យកត់សម្គាល់ ចំពោះប្រព័ន្ធអេកូឡូស៊ី ឬជីវៈចម្រុះ និងផលប៉ះពាល់តិចតួចពីការអភិវឌ្ឍទេសចរណ៍ធម្មជាតិ អាចត្រូវពិចារណាផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានការគិតពិចារណាអំពីទំនាក់ទំនងរវាងការអភិរក្ស និងអត្ថប្រយោជន៍ជាច្រើន ដែលត្រូវទាញយកពីក្នុងតំបន់នេះ។ សកម្មភាពផ្សេងៗទៀត ដូចជាការប្រមូលអនុផលព្រៃឈើ និងការនេសាទជាលក្ខណៈគ្រួសារដែលប្រើប្រាស់ឧបករណ៍ប្រពៃណីដោយសហគមន៍មូលដ្ឋាន ត្រូវបានអនុញ្ញាតតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

ជាគោលការណ៍រួម តំបន់ស្នូលត្រូវហ៊ុំព័ទ្ធជុំវិញដោយតំបន់អភិរក្ស ដែលមាន មុខងារជាតំបន់ទ្រនាប់ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីសកម្មភាពមនុស្ស ព្រោះជាតំបន់ស្នូល ដែលត្រូវការការពារកម្រិតខ្ពស់បំផុត។

## ៦.៣. តំបន់ប្រើប្រាស់ដោយចីរភាព

តំបន់ប្រើប្រាស់ដោយចីរភាព ត្រូវបានបញ្ជាក់ និងយល់ដឹងឱ្យបានច្បាស់លាស់ដោយអ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធ។ សម្បទានដីសេដ្ឋកិច្ច មិនត្រូវផ្តល់ជូនទេ នៅក្នុងតំបន់នេះ ព្រោះត្រូវបានប្រើប្រាស់ផ្លាស់ប្តូរពីគម្របព្រៃឈើទៅជាប្រភេទដំណាំឧស្សាហកម្ម ដែលផ្ទុយនឹងគោលបំណងតំបន់ប្រើប្រាស់ដោយចីរភាព។ ការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ (ឧទាហរណ៍ ការប្រមូលផល-អនុផលព្រៃឈើ ការដាំស្តារប្រភេទឈើក្នុងតំបន់ ការប្រមូលផល-អនុផលព្រៃឈើជាលក្ខណៈប្រពៃណី) នឹងត្រូវអនុវត្តន៍តាមគោលការណ៍ដកហូត ឬប្រមូលដោយនិរន្តរភាព ក្នុងលក្ខខណ្ឌសុខដុម្យនីយកម្ម ជាមួយនឹងធម្មជាតិ ដែលប្រើប្រាស់ធនធានធម្មជាតិ មិននាំឱ្យបង្កដល់ការខូចខាត ឬផ្លាស់ប្តូរធនធានធម្មជាតិដែលមានស្រាប់ដោយប្រភេទផ្សេងៗទៀត ឬការសាងសង់នៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗទៀត។ តំបន់អភិវឌ្ឍន៍ដោយចីរភាព នឹងត្រូវកំណត់បន្ទាប់ពីតំបន់ស្នូល ឬតំបន់អភិរក្ស និងតំបន់សហគមន៍ ដែលមានស្រាប់។ ការកំណត់តំបន់នេះ ត្រូវអនុលោមឱ្យស្របនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស។

ជាទូទៅ តំបន់ប្រើប្រាស់ដោយចីរភាព សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចមានឱកាសបន្ថែម ក្នុងការរកបរចិញ្ចឹមជិវិត។

យោងតាមវាក្យស័ព្ទ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ តំបន់ប្រើប្រាស់ដោយចីរភាពរួមមាន៖

- តំបន់អភិរក្សវប្បធម៌ធម្មជាតិ និងបេតិកភណ្ឌ
- តំបន់ទេសចរណ៍អភិរក្សសត្វព្រៃ និងសេវាកំសាន្ត
- តំបន់ស្តារធនធានជីវៈចម្រុះ
- សហគមន៍តំបន់ការពារធម្មជាតិ

- តំបន់រុក្ខឧទ្យាន
- តំបន់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមមានៈ ប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹក វារីអគ្គីសនី បង្គោលចរន្តអគ្គីសនី
- តំបន់ភូគព្ភសាស្ត្រ
- តំបន់អាជីវកម្មជ័រុក្ខជាតិ អនុគ្រោះដល់បរិស្ថានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ និងតំបន់ជុំវិញ។

នៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព អាចត្រូវបង្កើតតំបន់ស្នូល ឬតំបន់អភិរក្ស ដែលតំបន់ទាំងនោះមានលក្ខណវិនិច្ឆ័យចាំបាច់ដែលត្រូវបង្កើត ដើម្បីធានាបានការពារ និងអភិរក្សធនធានធម្មជាតិ ទីជម្រាល ប្រព័ន្ធផ្លូវទឹក ប្រភពទឹក និងបរិស្ថានធម្មជាតិ រួមទាំងសុខមាលភាពសាធារណៈ។...ល។

## ៦.៤. តំបន់សហគមន៍

តំបន់សហគមន៍ គឺជាតំបន់ស្មុគ្រស្មាញ ដោយសារវត្តមានភូមិ ដែលមានដីលំនៅដ្ឋាន ដីស្រែចំការ និងដីផ្សេងៗទៀត។ មានច្បាប់ពាក់ព័ន្ធ ត្រូវបានចែងទទួលស្គាល់ និងធានាសិទ្ធិរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងជនជាតិដើមភាគតិច។ ឯកសារច្បាប់ និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធ ត្រូវអនុវត្តន៍ចំពោះការកំណត់បែងចែកតំបន់សហគមន៍។ ឯកសារទាំងនេះ មានជាអាទិ៍ៈ

- ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ និងច្បាប់ភូមិបាលឆ្នាំ២០០១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ក្រុង ខេត្ត ស្រុក ឃុំ/សង្កាត់ ឆ្នាំ២០០៤
- អនុក្រឹត្យ លេខ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥
- អនុក្រឹត្យ ៨៣ ស្តីពីនីតិវិធី ស្តីពីការចុះបញ្ជីដីធ្លី របស់ជនជាតិដើមភាគតិចឆ្នាំ២០០៥
- សេចក្តីណែនាំ ស្តីពីការពង្រឹងប្រសិទ្ធភាពនៃប្រតិបត្តិការអនុវត្តគោលនយោបាយចាស់សកម្មភាពថ្មីរបស់រាជរដ្ឋាភិបាលលើវិស័យដីធ្លី លេខ ០១៩ សណន/កគជ ឆ្នាំ២០១២
- បទបញ្ជាស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច លេខ ០១បប ចុះខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលកម្ពុជា
- បទបញ្ជាស្តីពីវិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបការកាប់ដឹកជញ្ជូន ការប្រមូល ការស្តុកទុក និងការនាំចេញឈើក្រញូង លេខ០២ បប ចុះខែកុម្ភៈ ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- សារាចរស្តីពីការធ្វើឱ្យប្រសើរឡើង និងការគ្រប់គ្រងប្រសិទ្ធភាពសម្បទានដីសេដ្ឋកិច្ច (បទបញ្ជារបស់រាជរដ្ឋាភិបាល លេខ សរ០២ ឆ្នាំ២០០៧)
- សារាចរណែនាំស្តីពីវិធានការចាំបាច់នានា ក្នុងការពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ លេខ០៥ សរណន ចុះខែកុម្ភៈ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា
- ប្រកាសស្តីពីផល អនុផលព្រៃឈើដែលត្រូវហាមឃាត់ការប្រមូលផលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០០៥
- ប្រកាសស្តីពីចំណាត់ថ្នាក់ និងបញ្ជីឈ្មោះប្រភេទសត្វព្រៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០០៧

- ប្រកាសស្តីពី ចំណាត់ថ្នាក់ និងបញ្ជីឈ្មោះប្រភេទសត្វព្រៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០០៧
- គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិឆ្នាំ២០១៧

តំបន់សហគមន៍ ត្រូវបានការពារចំពោះដីទីលំនៅឋាន ដីដាំដំណាំ (ដីស្រែ ចំការ និងច្បារដំណាំ) និងដីសំណង់សាធារណៈ ដែលទាំងអស់នេះ ត្រូវចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនម្ចាស់ដី។

ការយកចិត្តទុកដាក់សិក្សាលក្ខណវិនិច្ឆ័យផ្នែកប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ចសង្គម ត្រូវអនុវត្តន៍តាមលក្ខណវិនិច្ឆ័យ ដូចតំបន់នានាដែរ ឬទៅតាមលក្ខណៈឋានលេខា និងភូមិសាស្ត្រ (លក្ខណៈភូមិសាស្ត្រ ព្រំព្រៃ អូរ ស្ទឹង បឹង ព្រែក ទន្លេ និងតំបន់ប្រភពទឹក តំបន់បេតិកភណ្ឌវប្បធម៌ និងតំបន់បេតិកភណ្ឌធម្មជាតិ តំបន់សំបូរជីវៈចម្រុះ) ដើម្បីរក្សាលំនឹងបរិស្ថានធម្មជាតិ សុខមាលភាពសាធារណៈ និងបង្កើនសមត្ថភាពទេសចរណ៍ និងប្រជាសហគមន៍បានយល់ដឹងពីការអនុវត្តក្នុងតំបន់របស់ខ្លួន និងតំបន់ដែលមានលក្ខខណ្ឌតឹងរ៉ឹងក្នុងការអនុវត្ត។ បន្ថែមពីនេះ ការប្រើប្រាស់តំបន់ណាមួយ សម្រាប់គោលបំណងយោធា សម្រាប់សុវត្ថិភាព និងសន្តិសុខជាតិ ត្រូវសិក្សាពីការកាត់បន្ថយផលប៉ះពាល់ដល់ប្រភេទរុក្ខជាតិសត្វ និងធនធានធម្មជាតិដ៏ទៃទៀត សម្រាប់គាំទ្រដល់ការអភិវឌ្ឍរយៈពេលវែង។

## ៧. ជំហានសំខាន់ៗសម្រាប់ការអនុវត្ត

គោលការណ៍ណែនាំនេះ មានជំហានសំខាន់ៗ ៥ សម្រាប់ការអនុវត្ត និងអាចធ្វើបច្ចុប្បន្នភាពនៅពេលដែលមានការសិក្សាស្រាវជ្រាវ ឬទទួលបានទិន្នន័យវិទ្យាសាស្ត្រថ្មីៗបន្ថែមទៀត។ ជំហាននីមួយៗអាចនឹងមានជំហានតូចៗមួយចំនួនទៀត ដើម្បីធានាបាននូវការអនុវត្តឱ្យបានលម្អិត និងប្រសិទ្ធភាពក្នុងការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ។ ជំហានសំខាន់ៗ សម្រាប់ការអនុវត្តទាំង៥ រួមមាន៖

### ៧.១. ការបង្កើតក្រុមការងាររៀបចំកំណត់បែងចែកតំបន់គ្រប់គ្រង

ក្រុមការងាររៀបចំកំណត់បែងចែកតំបន់គ្រប់គ្រង ត្រូវបង្កើតឡើងដោយក្រសួងបរិស្ថាន និងមានសមាសភាពដូចខាងក្រោម៖

- ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ជាប្រធាន
- ថ្នាក់ដឹកនាំអភិបាលនៃគណៈអភិបាលខេត្ត ជាអនុប្រធាន
- ប្រធាននាយកដ្ឋានមានសមត្ថកិច្ច ជាអនុប្រធាន
- ថ្នាក់ដឹកនាំនាយកដ្ឋានពាក់ព័ន្ធ ជាសមាជិក
- ថ្នាក់ដឹកនាំនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ជាសមាជិក
- ថ្នាក់ដឹកនាំនាយកដ្ឋានជីវៈចម្រុះ និងអនុសញ្ញា ជាសមាជិក
- ថ្នាក់ដឹកនាំមន្ទីរបរិស្ថានខេត្តមានសមត្ថកិច្ច ជាសមាជិក
- អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ជាសមាជិក
- ថ្នាក់ដឹកនាំការិយាល័យ និងមន្ត្រីបច្ចេកទេស ជាសមាជិក
- នាយកតំបន់ការពារធម្មជាតិមានសមត្ថកិច្ច ជាសមាជិក

- ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ជាសមាជិក
- អង្គភាព និងអ្នកពាក់ព័ន្ធផ្សេងទៀត ជាសមាជិក
- ភូមិ-ឃុំ/សង្កាត់ និងស្រុកពាក់ព័ន្ធ

## ៧.២. វិធីសាស្ត្រនៃការសិក្សា

ក. ជ្រើសរើសវិធីសាស្ត្រសិក្សា វាយតម្លៃដោយមានការចូលរួម និងសមស្របសម្រាប់ ការអនុវត្តទៅតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែងក្នុងការកំណត់បែងចែកតំបន់គ្រប់គ្រងតំបន់នីមួយៗ

ខ. ជ្រើសរើសអ្នកសំខាន់ៗក្នុងសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដើម្បីចូលរួមផ្តល់ទិន្នន័យ និងព័ត៌មានក្នុងការសិក្សាស្រាវជ្រាវ

គ. ប្រមូល និងប្រើប្រាស់ទិន្នន័យ និងព័ត៌មានដែលមានស្រាប់ជាមូលដ្ឋានសម្រាប់វិភាគ

ឃ. កំណត់តម្រូវការប្រភេទព័ត៌មាន ដែលឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ

ង. លទ្ធផលនៃការសិក្សាត្រូវបង្ហាញ និងពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ។

## ៧.៣. ការសិក្សាបឋម

ក. រៀបចំប្រជុំពិភាក្សា និងពិគ្រោះយោបល់ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីដំណើរការ និងជំហានៗនៃការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ និងរៀបចំផែនការសកម្មភាពការងារ

ខ. សិក្សាយល់ដឹងពីច្បាប់ស្តីពី តំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ គោលការណ៍ណែនាំ ទិន្នន័យ ព័ត៌មានដែលមានស្រាប់

គ. កំណត់អ្នកពាក់ព័ន្ធសំខាន់ៗ និងតាមវិស័យជំនាញ ដើម្បីជួបពិភាក្សាប្រមូលទិន្នន័យ ព័ត៌មាន និងរៀបចំសេចក្តីព្រាងផែនទីក្នុងតំបន់គោលដៅ ស្របនឹងចំណុច៥ នៃលក្ខណវិនិច្ឆ័យសម្រាប់កំណត់បែងចែកតំបន់ត្រឹមត្រូវ

ឃ. សិក្សាពិនិត្យអំពីលក្ខណវិនិច្ឆ័យ ផ្ទៀងផ្ទាត់ទិន្នន័យ និងរៀបចំសេចក្តីព្រាងផែនទីកំណត់តំបន់គ្រប់គ្រង។

## ៧.៤. ការសិក្សានៅទីវាល

ក. ប្រមូលទិន្នន័យនៅតាមតំបន់គោលដៅ

ខ. សិក្សាផ្ទាល់ដល់ទីកន្លែងស្តីពីសមាសភាគនៃលក្ខណវិនិច្ឆ័យនៃតំបន់នីមួយៗ និងការកំណត់តំបន់ដូចមានចែងក្នុងចំណុច៥ និង៦ នៃគោលការណ៍ណែនាំនេះ។

គ. ពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យបឋម និងទិន្នន័យនៅទីវាល និងរៀបចំសេចក្តីព្រាងផែនទីបែងចែកតំបន់គ្រប់គ្រងលើកទី២។

ឃ. ពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលពាក់ព័ន្ធ។

ចំណុចសំខាន់ៗដែលត្រូវពិគ្រោះយោបល់ មានជាអាទិ៍៖

១. សាវតានៃតំបន់

- ទីតាំង (ផ្ទៃដី ភូមិសាស្ត្រ រដ្ឋបាល)
- ប្រជាសាស្ត្រ (អាយុ ភេទ និងគ្រួសារ បរិបទសង្គម និងសេដ្ឋកិច្ច ភាសា ការអប់រំ មុខរបរ ជនជាតិ សាសនា ចំណូល និងសុខភាព ផ្អែកលើគោលនយោបាយ សេដ្ឋកិច្ច និងប្រជាសាស្ត្រ)
- ធនធានធម្មជាតិ (រុក្ខជាតិ សត្វ ធនធានរ៉ែ ប្រភពទឹក និងបណ្ដាញធនធានទឹក)
- ការប្រើប្រាស់(មានច្បាប់ អត់ច្បាប់ លក្ខណៈប្រពៃណី)
- ការគ្រប់គ្រង (តាមដំណាក់កាលនីមួយៗរហូតដល់បច្ចុប្បន្ន)

២. លទ្ធផលសិក្សាអំពីលក្ខណវិនិច្ឆ័យ ចំណុច៥ និង៦ នៃគោលការណ៍ណែនាំនេះ

៣. សេចក្ដីព្រាងផែនទីកំណត់បែងចែងតំបន់គ្រប់គ្រង

៤. សរុបលទ្ធផលពិគ្រោះយោបល់ និងរៀបចំសេចក្ដីព្រាងផែនទីកំណត់បែងចែងតំបន់គ្រប់គ្រង

## ៧.៥. បញ្ចប់សេចក្ដីព្រាង និងអនុម័ត លទ្ធផលការកំណត់បែងចែកតំបន់គ្រប់គ្រង

ក. ប្រជុំផ្ទៃក្នុងនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដើម្បីពិនិត្យវាយតម្លៃ និងសរុបលទ្ធផលនៃសេចក្ដីព្រាងចុងក្រោយ

ខ. ប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីពិនិត្យ និងវាយតម្លៃសេចក្ដីព្រាងចុងក្រោយ

គ. ស្នើសុំការអនុម័តពីរាជរដ្ឋាភិបាល

# ៨. វិធានការសម្រាប់ការកំណត់បែងចែកតំបន់គ្រប់គ្រងប្រកបដោយប្រសិទ្ធភាព

ក. ការកំណត់បែងចែកតំបន់គ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធ ជាពិសេស អ្នកដែលងាយនឹងរងផលប៉ះពាល់ពីការកំណត់បែងចែកតំបន់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។ ការកំណត់បែងចែកតំបន់គ្រប់គ្រងដោយមានការចូលរួមពីភាគីពាក់ព័ន្ធ អាចធ្វើឱ្យសម្រេចបាននូវតុល្យភាពរវាងការអភិរក្ស និងការអភិវឌ្ឍ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងក្នុងការកំណត់បែងចែកតំបន់គ្រប់គ្រង ត្រូវអនុលោមតាមលក្ខណវិនិច្ឆ័យ និងគោលការណ៍បែងចែកតំបន់ អភិបាលកិច្ចល្អ ការកៀងគរមូលនិធិហិរញ្ញប្បទាន និងឋវិការរដ្ឋាភិបាលសម្រាប់គាំទ្រដល់ការប្រតិបត្តិ។

ខ. ការអនុវត្តគោលការណ៍ណែនាំនេះ ត្រូវពិនិត្យវាយតម្លៃ ដើម្បីបញ្ចូលបន្ថែមពីលក្ខណវិនិច្ឆ័យ ឬគោលការណ៍កំណត់បែងចែកតំបន់គ្រប់គ្រង ទៅតាមស្ថានភាពតម្រូវការជាក់ស្ដែងដោយឡែកៗនៃតំបន់ការពារធម្មជាតិនីមួយៗ។

គ. ត្រូវមានផែនការតាមដានត្រួតពិនិត្យ និងវាយតម្លៃស្ដីពីស្ថានភាពជាក់ស្ដែងនៃតំបន់គ្រប់គ្រងនីមួយៗ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការធ្វើបច្ចុប្បន្នភាពតំបន់គ្រប់គ្រង និងប្រតិបត្តិផែនការសកម្មភាពគ្រប់គ្រងតំបន់។

ឃ. គោលការណ៍ណែនាំនេះ ត្រូវធ្វើបច្ចុប្បន្នភាពដោយយោងទៅតាមលទ្ធផលស្រាវជ្រាវវិទ្យាសាស្រ្ត និងទិន្នន័យព័ត៌មាន ឬតម្រូវការចាំបាច់នៃតំបន់ការពារធម្មជាតិនីមួយៗ។

ង. ដើម្បីគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវរៀបចំផែនការគ្រប់គ្រងឱ្យស្របទៅនឹងគោលបំណងនៃតំបន់នីមួយៗ នៃតំបន់គ្រប់គ្រង ដោយមានការចូលរួមពីអង្គភាព មន្ទីរជំនាញពាក់ព័ន្ធ សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អ្នកឯកទេសជំនាញ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ។

ច. ចាំបាច់ត្រូវមានគោលការណ៍ណែនាំស្តីពី ការរៀបចំផែនការសកម្មភាពគ្រប់គ្រងតំបន់ការពារធម្មជាតិ ដើម្បីរៀបចំផែនការសកម្មភាពនេះឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ស្របតាមគោលនយោបាយរាជរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្ត លក្ខខណ្ឌបច្ចេកទេស ក្របខណ្ឌអនុសញ្ញា និងកិច្ចព្រមព្រៀងតំបន់ ឬសកល ស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗ និងមានការចូលរួមពីបណ្តាភាគីពាក់ព័ន្ធ។

# ឧបសម្ព័ន្ធ១៖ សត្វដែលជិតផុតពូជ និងតម្រូវការជម្រក

| ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | ស្ថានភាព | តម្រូវការជម្រក (គម$^២$) |
|---|---|---|---|---|
| **ក. ថនិកសត្វ** | | | | |
| *ដំរីអាស៊ី* | *Asian elephant* | *Elephas maximus* | *ជិតផុតពូជ* | *១០០-៨០០គម$^២$ អាស្រ័យលើការសិក្សាទំហំដីពិតប្រាកដ ដែលបានអង្កេតប្រមូលទិន្នន័យ និងព័ត៌មាន* |
| *ខ្លាដំបង* | *Tiger* | *Panthera tigris* | *ជិតផុតពូជ* | *២០០-២៥០គម$^២$ ទំហំដែនដីអាស្រ័យលើដង់ស៊ីតេសត្វរំពារ* |
| *ខ្លាឃ្មុំធំ* | *Asiatic black bear* | *Ursus thibetanus* | *ងាយរងគ្រោះ* | |
| *ខ្លាឃ្មុំតូច* | *Malayan sun bear* | *Helarctos malayanus* | *ងាយរងគ្រោះ* | |
| *ខ្លាពពក* | *clouded leopard* | *Neofelis nebulosa* | *ងាយរងគ្រោះ* | |
| *ខ្លាត្រី* | *fishing cat* | *Prionailurus viverrinus* | *ជិតផុតពូជ* | |
| *ខ្លាលឿងមាស* | *Asian golden cat* | *Catopuma temminckii* | *ជិតទទួលរងការគំរាមកំហែង* | |
| *ខ្លាភ្លីថ្មកែវ* | *marbled cat* | *Pardofelis marmorata* | *ជិតទទួលរងការគំរាមកំហែង* | |
| *រមាំង* | *Eld's deer* | *Rucervus eldii* | *ជិតផុតពូជ* | |
| *កែះ* | *Chinese serow* | *Capricornis milneedwardsii* | *ជិតទទួលរងការគំរាមកំហែង* | |
| *ប្រើសស្បូវ* | *Sambar deer* | *Rusa unicolor* | *ងាយរងគ្រោះ* | |
| *ខ្ទីង* | *gaur* | *Bos gaurus* | *ងាយរងគ្រោះ* | |
| *ទន្សោង* | *Banteng* | *Bos javanicus* | *ជិតផុតពូជ* | *រហូតទៅដល់៤៥គម$^២$* |
| *ពង្រូល* | *Sunda pangolin* | *Manis javanica* | *ជិតផុតពូជខ្លាំងបំផុត* | |
| *ទោចម្កុជ* | *pileated gibbon* | *Hylobate pileatus* | *ជិតផុតពូជ* | |
| *ទោចថ្ពាល់លឿង* | *yellow cheeked gibbon* | *Nomascus gabriellae* | *ជិតផុតពូជ* | |
| *ស្វាកន្ទុយស* | *Douc langur* | *Pygathrix nemaeus* | *ជិតផុតពូជ* | |
| *ស្វាព្រាម* | *silver langur* | *Trachypithecus germaini* | *ជិតផុតពូជ* | |
| *រញ៉េប្របផេះ* | *slow loris* | *Nycticebus javanicus* | *ជិតផុតពូជខ្លាំងបំផុត* | |
| *រញ៉េភ្លើង* | *pigmy loris* | *Nycticebus pygmaeus* | *ងាយរងគ្រោះ* | |
| *ស្វាត្រោស* | *pig-tailed macaque* | *Macaca nemestrina* | *ងាយរងគ្រោះ* | |
| *ស្វាក្តាម* | *long-tailed macaque* | *Macaca fascicularis* | *មិនសូវព្រួយបារម្ភ* | |
| *ឆ្កែព្រៃ* | *Dhole* | *Cuon alpinus* | *ជិតផុតពូជ* | |
| **ខ.សត្វស្លាប** | | | | |
| *សត្វត្រយ៉ងយក្ស* | *giant ibis* | *Pseudibis gigantean* | *ជិតផុតពូជខ្លាំងបំផុត* | |
| *ត្រដក់ធំ* | *Greater adjutant* | *Leptoptilus dubius* | *ជិតផុតពូជ* | |
| *កេងកងធំ* | *great hornbill* | *Buceros bicornis* | *ជិតផុតពូជ* | |
| *ត្មាតផេះ* | *White-rumped Vulture* | *Gyps bengalensis* | *ជិតផុតពូជខ្លាំងបំផុត* | |

| ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | ស្ថានភាព | តម្រូវការជម្រក (គម²) |
|---|---|---|---|---|
| ត្មាតត្នោត | *Slender-billed Vulture* | *Gyps tenuirostris* | ជិតផុតពូជខ្លាំងបំផុត | |
| ត្មាតភ្លើង | *Red-headed Vulture* | *Sarcogyps calvus* | ជិតផុតពូជខ្លាំងបំផុត | |
| ក្រៀលក្បាលក្រហម | *sarus crane* | *Antigone antigone* | ងាយរងគ្រោះ | |
| អង្កត់ខ្មៅ (ដំបងក្រញូង) | *black-necked stork* | *Ephippiorhynchus asianticus* | ជិតទទួលរងការគំរាមកំហែង | |
| រនាលពណ៌ | *painted stork* | *Mycteria leucocephala* | ជិតទទួលរងការគំរាមកំហែង | |
| ទុងប្រផេះ | *spot-billed pelican* | *Pelecanus philippensis* | ជិតទទួលរងការគំរាមកំហែង | |
| ទាព្រៃស្លាបស | *White-winged duck* | *Cairina scutulata* | ជិតផុតពូជ | |
| កំប្រុកស្លាបតូច | *Particoloured flying squirrel* | *Hylopetes alboniger* | ជិតផុតពូជ | |
| ទាព្រៃស្លាបស | *White-winged Duck* | *Asarcornis scutulata* | ជិតផុតពូជ | |
| **គ.ឧរង្គសត្វ និងត្រី** | | | | |
| ក្រពើភ្នំ | *Siamese crocodile* | *Crocodylus siamensis* | ជិតផុតពូជខ្លាំងបំផុត | |
| អណ្តើកហ្លួង | *Royal turtle* | *Batagur baska* | ជិតផុតពូជខ្លាំងបំផុត | |
| កន្ធាយក្បាលកង្កែប | *giant soft-shell turtle* | *Rafetus swinhoei* | ជិតផុតពូជខ្លាំងបំផុត | |
| អណ្តើកព្រិច | *elongated tortoise* | *Indotestudo elongate* | ជិតផុតពូជ | |
| អណ្តើកសកល | *yellow-headed temple turtle* | *Heosemys annanadalii* | ជិតផុតពូជ | |
| ពស់ថ្លាន់ស្រកាហូល | *Burmese python* | *Python bivittatus* | ងាយរងគ្រោះ | |
| ពស់វែករនាម | *King cobra* | *Ophiophagus Hannah* | ងាយរងគ្រោះ | |
| ពស់វែកក្របី | *Monocled Cobra* | *Naja kaouthia* | ងាយរងគ្រោះ | |
| ត្រីតាពក | *Asian arowana* | *Scleropages formosus* | ជិតផុតពូជ | |
| អណ្តើកហ្លួង | *Batagur* | *Batagur Baska* | ជិតផុតពូជខ្លាំងបំផុត | |
| ភេរោមច្រមុះ | *Hairy-nosed Otter* | *Lutra sumatrana* | ជិតផុតពូជ | |
| ក្ងោកបៃតង | *Green Peafowl* | *Pavo muticus* | ជិតផុតពូជ | |
| ត្រីក្បក | *Fish—family Clupeidae* | *Tenualosa thibaudeaui* | ជិតផុតពូជ | |
| ត្រី ត្រសក់ | *Jullien's golden carp* | *Probarbus jullieni* | ជិតផុតពូជ | |
| ត្រីរាជ | *Giant catfish* | *Pangasianodon gigas* | ជិតផុតពូជ | |

ចំណាំ៖ សត្វជាច្រើនទៀតនឹងត្រូវបានបន្ថែមទៅក្នុងតារាង២ នៅពេលមានទិន្នន័យថ្មីៗ។

## ឧបសម្ព័ន្ធ២៖ តំបន់អាទិភាពសម្រាប់កំណត់តំបន់នីមួយៗ ក្នុងតំបន់ការពារធម្មជាតិ




រូបភាព១ ៖ តំបន់អាទិភាពសម្រាប់កំណត់តំបន់នីមួយៗ ក្នុងតំបន់ការពារធម្មជាតិ

ការបកស្រាយរូបភាព១៖ លក្ខណវិនិច្ឆ័យ សេដ្ឋកិច្ច សង្គម និងអេកូឡូស៊ី មានពិន្ទុ អាទីភាពខ្ពស់មួយសម្រាប់យកមកពិចារណា នៃតំបន់នីមួយៗ ១០០% ប៉ុន្តែមានការប្រែប្រួលទៅតាមតំបន់រៀងៗខ្លួន។ ឧទាហរណ៍ តំបន់ស្នូលនឹងមានពិន្ទុលក្ខណវិនិច្ឆ័យអេកូឡូស៊ីខ្ពស់រហូតដល់ ១០០% នៅពេលដែលលក្ខណវិនិច្ឆ័យសេដ្ឋកិច្ច-សង្គម គឺមានដល់កំរិតសូន្យ។ ផ្ទុយទៅវិញ ពិន្ទុអាទិភាពនៃលក្ខណៈ អេកូឡូស៊ី គឺឡើងដល់កំរិតសូន្យនៅពេលលក្ខណវិនិច្ឆ័យសេដ្ឋកិច្ច-សង្គម គឺឡើងដល់ ១០០% សម្រាប់តំបន់សហគមន៍។

## ឧបសម្ព័ន្ធ៣៖ ឧទាហរណ៍ពីការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងសម្ភតិកម្ម តំបន់ការពារធម្មជាតិមួយ




រូបភាព២៖ ឧទាហរណ៍ពីការកំណត់បែងចែកតំបន់គ្រប់គ្រងក្នុងសម្ភតិកម្មតំបន់ការពារធម្មជាតិមួយ

ឧទាហរណ៍នៃដំណើរការ៖ ប្រភេទសត្វ A(ដូចជាដំរី ឬខ្លាដំបង) ត្រូវការ ២០គម² ប៉ុន្តែនៅក្បែរនោះ ក៏មានប្រភេទសត្វផ្សេងទៀត ដែលជិតផុតពូជផងដែរ៖ ប្រភេទ រុក្ខជាតិ បក្សី និងល្មូន (ចំណុចពណ៌ក្រហម) នៅក្នុងតំបន់ការពារធម្មជាតិខាងលើ។ ដូច្នេះ តំបន់ស្នូលពិតប្រាកដ មានតម្រូវការជម្រកសម្រាប់សត្វទាំងពីរប្រភេទ (ដំរី និងខ្លា) ទីតាំងនៃប្រភេទរុក្ខជាតិ បក្សី និងល្មូន។ ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ គឺមានសារៈសំខាន់ ដើម្បីយល់ដឹងអំពីទីតាំងនៃប្រភេទសត្វជិតផុតពូជនៅក្នុងតំបន់ការពារធម្មជាតិ។

# ឧបសម្ព័ន្ធ៤៖ ផែនទីប្រព័ន្ធតំបន់ការពារធម្មជាតិ និង របៀងអតិរក្សជីវៈចម្រុះ



# បញ្ជីរាយនាមតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
# ពីឆ្នាំ១៩៩៣-២០១៨

| កូដ | តំបន់ការពារធម្មជាតិ | ស្ថិតក្នុងខេត្ត | ផ្ទៃក្រឡា(ហ.ត) | ព្រះរាជក្រឹត្យ/អនុក្រឹត្យ |
|---|---|---|---|---|
| ឧទ្យានជាតិ(ឧ.ជ) ចំនួន១២តំបន់ | | | ១,៧៧០,០៦២ | |
| *ឧ.ជ០១* | កែប | កែប | ១,១៥២ | អនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៣ |
| *ឧ.ជ០២* | វីរៈនសៃ-សៀមប៉ាង | ស្ទឹងត្រែង និងរតនៈគិរី | ៥៧,៤៦៩ | អនុក្រឹត្យលេខៈ ៧៧ អនក្រ.បក ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ឧ.ជ០៣* | ជួរភ្នំក្រវាញកណ្តាល | កោះកុង ពោធិ៍សាត់ និងកំពង់ស្ពឺ | ៤០១,៣១៣ | អនុក្រឹត្យលេខៈ ៨១ អនក្រ.បក ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ឧ.ជ០៤* | ព្រះសុរាម្រិត-កុសមៈ (គិរីរម្យ) | កំពង់ស្ពឺ កំពត និងព្រះសីហនុ | ៣៥,២៣២ | អនុក្រឹត្យលេខ១៧១ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ |
| *ឧ.ជ០៥* | ព្រះមុនីវង្ស (បូកគោ) | កំពត និងព្រះសីហនុ | ១៥៤,៤៥៨ | អនុក្រឹត្យលេខ១៧១ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ |
| *ឧ.ជ០៦* | អូយ៉ាដាវ | រតនៈគិរី | ១០១,៣៤៨ | អនុក្រឹត្យលេខៈ ៨២ អនក្រ.បក ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ឧ.ជ០៧* | ជួរភ្នំក្រវាញខាងត្បូង | កោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និងព្រះសីហនុ | ៤១០,៣៩២ | អនុក្រឹត្យលេខៈ ៨៩ អនក្រ.បក ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ឧ.ជ០៨* | សមុទ្រកោះរ៉ុង | ព្រះសីហនុ កោះកុង | ៥២,៤៤៨ | អនុក្រឹត្យលេខៈ ១៤ អនក្រ.បក ចុះថ្ងៃទី ០៨ កុម្ភៈ ២០១៨ |
| *ឧ.ជ៩៣* | ព្រះសីហនុ (រាម) | ព្រះសីហនុ | ១៥,០០០ | ព្រះរាជក្រឹត្យលេខៈ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ឧ.ជ៩៣* | បូទុមសាគរ | កោះកុង | ១៧១,២៥០ | ព្រះរាជក្រឹត្យលេខៈ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ឧ.ជ៩៣* | ព្រះជ័យវរ្ម័ន-នរោត្តម (ភ្នំគូលែន | សៀមរាប | ៣៧,៥០០ | ព្រះរាជក្រឹត្យលេខៈ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ឧ.ជ៩៣* | វីរៈជ័យ | រតនៈគិរី និងស្ទឹងត្រែង | ៣៣២,៥០០ | ព្រះរាជក្រឹត្យលេខៈ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ឧ.ជនិ៣០១* | កោះរ៉ុង | ព្រះសីហនុ | *(-២៦៥៥.៣៥)* | អនុក្រឹត្យលេខៈ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៣ កញ្ញា ២០១៦ |
| ដែនជម្រកសត្វព្រៃ(ដ.ស)ចំនួន១៨តំបន់ | | | ៣,៤៣៣,១២២ | |
| *ដ.ស០១* | លំផាត់ | រតនៈគិរី និងមណ្ឌលគិរី | ២៥០,០០០ | អនុក្រឹត្យលេខៈ ០៤ អនក្រ.បក ចុះថ្ងៃទី ០៥ មករា ២០១៧ |
| *ដ.ស០២* | ភ្នំព្រេច | មណ្ឌលគិរី | ២២២,៥០០ | អនុក្រឹត្យលេខៈ ០៥ អនក្រ.បក ចុះថ្ងៃទី ០៥ មករា ២០១៧ |
| *ដ.ស០៣* | ព្រៃឡង់ | ស្ទឹងត្រែង កំពង់ធំ ក្រចេះ និងព្រះវិហារ | ៤៣១,៦៨៣ | អនុក្រឹត្យលេខៈ ៧៤ អនក្រ.បក ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ដ.ស០៤* | ព្រះរការ | ព្រះវិហារ | ៩០,៣៦១ | អនុក្រឹត្យលេខៈ ៧៥ អនក្រ.បក ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ដ.ស០៥* | សៀមប៉ាងខាងលិច | ស្ទឹងត្រែង | ៦៥,៣៨៩ | អនុក្រឹត្យលេខៈ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ដ.ស០៦* | ឆែប | ព្រះវិហារ និងស្ទឹងត្រែង | ១៩០,០២៧ | អនុក្រឹត្យលេខៈ ៧៩ អនក្រ.បក ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ដ.ស០៧* | តាតៃ | កោះកុង | ១៤៤,២៧៥ | អនុក្រឹត្យលេខៈ ៨០ អនក្រ.បក ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |

| កូដ | តំបន់ការពារធម្មជាតិ | ស្ថិតក្នុងខេត្ត | ផ្ទៃក្រឡា(ហ.ត) | ព្រះរាជក្រឹត្យ/អនុក្រឹត្យ |
|---|---|---|---|---|
| *ជ.សខ៨* | កែវសីមា | មណ្ឌលគិរី និងក្រចេះ | ២៩២,៦៩០ | អនុក្រឹត្យលេខ: ៨៣ អនក្រ.បក<br>ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ជ.សខ៩* | ស្រែពក | មណ្ឌលគិរី | ៣៧២,៩៧១ | អនុក្រឹត្យលេខ: ៨៥ អនក្រ.បក<br>ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ជ.ស១០* | សៀមប៉ាង | ស្ទឹងត្រែង | ៦៦,៩៣២ | អនុក្រឹត្យលេខ: ៨៦ អនក្រ.បក<br>ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ជ.ស១១* | ភ្នំត្នោត-ភ្នំពក | ព្រះវិហារ និងសៀមរាប | *(៤២,០៩៧)* | អនុក្រឹត្យលេខ: ១៤៣ អនក្រ.បក<br>ចុះថ្ងៃទី ៣១ សីហា ២០១៧ |
| *ជ.ស១២* | សង្ឃរក្ខាវ័ន | ឧត្តរមានជ័យ | *៣០២៥៤*<br>*(-២៧៧១០)* | អនុក្រឹត្យលេខ: ៤៩ អនក្រ.បក<br>ចុះថ្ងៃទី ៥ មេសា ២០១៨ |
| *ជ.ស៩៣* | ភ្នំឱរ៉ាល់ | កំពង់ស្ពឺ ពោធិ៍សាត់ កំពង់ឆ្នាំង | ២៥៣,៧៥០ | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ជ.ស៩៣* | ពាមក្រសោប | កោះកុង | ២៣,៧៥០ | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ជ.ស៩៣* | ភ្នំសំកុស | ពោធិ៍សាត់ បាត់ដំបង និងកោះក | ៣៣៣,៧៥០ | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ជ.ស៩៣* | គូលែន-ព្រហ្មទេព | សៀមរាប ព្រះវិហារ និងកំពង់ធំ | ៤០២,៥០០ | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ជ.ស៩៣* | បឹងពែរ | សៀមរាប ព្រះវិហារ និងកំពង់ធំ | ២៤២,៥០០ | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ជ.ស៩៣* | ភ្នំណាមលៀរ | មណ្ឌលគិរី | ៤៧,៥០០ | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ជ.សនិ៣០១* | នោមដូនសំ | បាត់ដំបង និងបន្ទាយមានជ័យ | *(១៧៨៧៥០)* | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ជ.សនិ៣០២* | ស្នួល | ក្រចេះ | *(៧៥០០០)* | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| **តំបន់ការពារទេសភាព(ក.ទ)ចំនួន១១តំបន់** | | | **១៥១,២០៨** | |
| *ក.ទ០១* | អន្លង់ព្រីង | កំពត | ២១៧ | អនុក្រឹត្យលេខ: ០៤ អនក្រ.បក<br>ចុះថ្ងៃទី ០៦ មករា ២០១១ |
| *ក.ទ០២* | ទំនាបខាងជើងទន្លេសាប | កំពង់ធំ និងខេត្តសៀមរាប | ៣១,១៥៩ | អនុក្រឹត្យលេខ: ៨៨ អនក្រ.បក<br>ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| *ក.ទ០៣* | បឹងព្រែកល្ពៅ | តាកែវ | ៨,៣០៥ | អនុក្រឹត្យលេខ: ១៤៩ អនក្រ.បក<br>ចុះថ្ងៃទី ១៥ តុលា ២០០៧ |
| *ក.ទ០៤* | អាងត្រពាំងថ្ម | បន្ទាយមានជ័យ | ១២,៦៥០ | ព្រះរាជក្រឹត្យលេខ: ជស/រកត/០២០០/១១០<br>ចុះថ្ងៃទី ២២ កុម្ភៈ ២០០០ |
| *ក.ទ០៥* | បឹងព្រែកទប់ | ព្រះសីហនុ | ១៦ | អនុក្រឹត្យលេខ: ១៨៧ អនក្រ.បក<br>ចុះថ្ងៃទី ១៣ កញ្ញា ២០១៦ |
| *ក.ទ០៦* | ប្រាសាទបាកាន (ព្រះខ័នកំពង់ | ព្រះវិហារ | (២,១២៤) | អនុក្រឹត្យលេខ: ១៤៤ អនក្រ.បក<br>ចុះថ្ងៃទី ៣១ សីហា ២០១៧ |
| *ក.ទ០៧* | នោមដូនសំ | បន្ទាយមានជ័យ | ១,៤២៣ | អនុក្រឹត្យលេខ: ១៥ អនក្រ.បក<br>ចុះថ្ងៃទី ២០ ធ្នូ ២០១៧ |
| *ក.ទ០៨* | សំបូរព្រៃគុក | កំពង់ធំ | ៤៣៨ | អនុក្រឹត្យលេខ: ៣៩ អនក្រ.បក<br>ចុះថ្ងៃទី ១៣ មិនា ២០១៨ |
| *ក.ទ៩៣* | អង្គរ | សៀមរាប | ១០,៨០០ | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ក.ទ៩៣* | បន្ទាយឆ្មារ | បន្ទាយមានជ័យ និងឧត្តរមានជ័ | ៨១,២០០ | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ក.ទ៩៣* | ព្រះវិហារ | ព្រះវិហារ | ៥,០០០ | ព្រះរាជក្រឹត្យលេខ: ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| **តំបន់ប្រើប្រាស់ច្រើនយ៉ាង(ប.ប)ចំនួន៧តំបន់** | | | **៤១៥,៥៧១** | |
| *ប.ប០១* | ពញាក្រែក | ត្បូងឃ្មុំ | ១៩៩ | អនុក្រឹត្យលេខ: ៨៧ អនក្រ.បក<br>ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |

| កូដ | តំបន់ការពារធម្មជាតិ | ស្ថិតក្នុងខេត្ត | ផ្ទៃក្រឡា(ហ.ត) | ព្រះរាជក្រឹត្យ/អនុក្រឹត្យ |
|---|---|---|---|---|
| *ប.ឋ០២* | ព្រែកទឹកសាបក្បាលឆាយ | ព្រះសីហនុ | ៥,៥២០ | អនុក្រឹត្យលេខៈ ១១៦ អនក្រ.បក<br>ចុះថ្ងៃទី ០៥ មិថុនា ២០១៦ |
| *ប.ឋ០៣* | ភ្នំនាងកង្រី-ភ្នំទូកមាស | កំពង់ឆ្នាំង | ៥,០៦៣ | អនុក្រឹត្យលេខៈ ២០០ អនក្រ.បក<br>ចុះថ្ងៃទី ២៨ វិច្ឆិកា ២០១៧ |
| *ប.ឋ០៤* | សសរស្តម្ភសត្វតោ | ក្រចេះ | ៨៣៩ | អនុក្រឹត្យលេខៈ ២០១ អនក្រ.បក<br>ចុះថ្ងៃទី ២៨ វិច្ឆិកា ២០១៧ |
| *ប.ឋ៩៣* | ដងពែង | កោះកុង | ២៧,៧០០ | ព្រះរាជក្រឹត្យលេខៈ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ប.ឋ៩៣* | សំឡូត | ប៉ៃលិន និងបាត់ដំបង | ៦០,០០០ | ព្រះរាជក្រឹត្យលេខៈ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| *ប.ឋ៩៣* | ទន្លេសាប | កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងសៀមរាប | ៣១៦,២៥០ | ព្រះរាជក្រឹត្យលេខៈ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ |
| | *តំបន់ស្នូលបឹងទន្លេឆ្មារ (តំបន់រ៉ាំ* | កំពង់ធំ | *(១៤,៥៦០)* | ព្រះរាជក្រឹត្យលេខៈ នស/រកត/០៤០១/០៧០<br>ចុះថ្ងៃទី ១០ មេសា ២០០១ |
| | *តំបន់ស្នូលព្រែកទាល់ (តំបន់រ៉ាំ* | បាត់ដំបង | *(២១,៣៤២)* | អនុក្រឹត្យលេខៈ ៨៧ អនក្រ.បក<br>ចុះថ្ងៃទី ០៩ ឧសភា ២០១៦ |
| | *តំបន់ស្នូលស្ទឹងសែន* | *កំពង់ធំ* | *(៦,៣៥៥)* | ព្រះរាជក្រឹត្យលេខៈ នស/រកត/០៤០១/០៧០<br>ចុះថ្ងៃទី ១០ មេសា ២០០១ |
| **តំបន់រ៉ាមសារ(រ.ស)ចំនួន៤តំបន់** | | | **១៤,៦០០** | |
| *រ.ស០១* | ស្ទឹងត្រែង | ស្ទឹងត្រែង | ១៤,៦០០ | ព្រះរាជក្រមលេខៈ នស.រកម.១២៩៦.៣៤<br>ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៦ |
| | *(កោះកាពិ)* | កោះកុង | *(១,២០០)* | ព្រះរាជក្រមលេខៈ នស.រកម.១២៩៦.៣៤<br>ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៦ |
| | *(បឹងទន្លេឆ្មារ)* | *កំពង់ធំ* | *(១៤,៥៦០)* | ព្រះរាជក្រមលេខៈ នស.រកម.១២៩៦.៣៤<br>ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៦ |
| | *(ព្រែកទាល់)* | *បាត់ដំបង* | *(២១,៣៤២)* | អនុក្រឹត្យលេខៈ ១៣៩ អនក្រ.បក<br>ចុះថ្ងៃទី ០២ តុលា ២០១៥ |
| | **តំបន់បេតិកភណ្ឌធម្មជាតិ(ប.ភ)ចំនួន២តំបន់** | | **២៤,៦៥៤** | |
| *ប.ភ០១* | ភ្នំត្បែង | ព្រះវិហារ | ២៤,៦៥៤ | អនុក្រឹត្យលេខៈ ១៨៩ អនក្រ.បក<br>ចុះថ្ងៃទី ១៣ កញ្ញា ២០១៦ |
| *ប.ភ០២* | ភ្នំយ៉ាត | ប៉ៃលិន | (៣១.៩៥១) | អនុក្រឹត្យលេខៈ ១០០ អនក្រ.បក<br>ចុះថ្ងៃទី ១៩ មិថុនា ២០១៦ |
| *របជ០១* | **របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ** | | **១,៤២៧,៩៤០** | |
| | *របៀងអភិរក្សជីវៈចម្រុះឦសាន* | | *-៧៥៧,៦៦១* | អនុក្រឹត្យលេខៈ ០៧ អនក្រ.បក<br>ចុះថ្ងៃទី ២៦ មករា ២០១៧ |
| | *របៀងអភិរក្សជីវៈចម្រុះឧត្តរ* | | *(៥០០,៨១០)* | អនុក្រឹត្យលេខៈ ០៧ អនក្រ.បក<br>ចុះថ្ងៃទី ២៦ មករា ២០១៧ |
| | *របៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ* | | *(១៦៩,៤៦៩)* | អនុក្រឹត្យលេខៈ ០៧ អនក្រ.បក<br>ចុះថ្ងៃទី ២៦ មករា ២០១៧ |
| | **សរុបផ្ទៃដី** | | **៧,២៣៧,១៥៧** | |

**កំណត់សម្គាល់៖**

១. តំបន់ប្រើប្រាស់ច្រើនយ៉ាង ទន្លេសាប នៃតំបន់បបនីយជីវមណ្ឌលបឹងទន្លេសាប ចែកចេញជា ០៣
តំបន់ស្នូលគឺ បឹងទន្លេឆ្មារ ព្រែកទាល់ និងស្ទឹងសែន

២. របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ចែកចេញជា ០៣ របៀងអភិរក្សជីវៈចម្រុះគឺ ព្រៀសាន ឧត្តរ និងជួរភ្នំក្រវាញ

៣. តំបន់រ៉ាមសារកោះកាពិ ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប និង ឧទ្យានជាតិបុ

៤. ដែនជម្រកសត្វព្រៃភ្នំត្នោត-ភ្នំពក ស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះឧត្តរ

៥. តំបន់ការពារទេសភាព ប្រាសាទបាកាន (ព្រះខ័នកំពង់ស្វាយ) ស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះឧត្តរ និងដែនជម្រកសត្វព្រៃបឹងពែរ

៦. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំយ៉ាត ស្ថិតនៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត

៧. ដែនជម្រកសត្វព្រៃសង្ឃរុក្ខាវ័ន ស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះឧត្តរ ចំនួន

៨. ឧ.ជ/ជ.ស/ក.ទ/ប.ប៩៣ ជាតំបន់ការពារធម្មជាតិដែលបង្កើតដោយព្រះរាជក្រឹត្យលេខៈ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣

៩. ឧ.ជនិរា/ជ សនិរា ជាតំបន់ការពារធម្មជាតិដែលត្រូវបាននិរាករណ៍

# ឯកសារយោង


Jingfors, K. (2017) Report on Zoning Guidelines for Protected Areas and Biodiversity Conservation Corridors in Cambodia (DRAFT). UNDP, Cambodia

Ervin, J. (2003) WWF: Rapid Assessment and Prioritization of Protected Area Management (RAPPAM) Methodology. WWF, Gland, Switzerland

MacKinnon, J. R. (1997) Protected areas system review of the Indo-Malayan Realm. Gland, Switzerland: the Asian Bureau for Conservation (ABC) and the World Conservation Monitoring Centre (WCMC)

Fernando, Vorsak and Sam Oeun (2014) Report on mapping and proposed zonation of Lomphat Wildlife Sanctuary. BirdLife and PRCF, Cambodia

MoE (2010) Fourth National Report to the Convention On Biological Diversity. Phnom Penh, Cambodia, 103 pp

Naughton, L.;2(2007) Zoning for Conservation and Development in Protected Areas. Collaborative Land Use Planning, Tenure Brief, University of Winsconsin, Madison.

Sunquist, M. E. (1981) The social organization of tigers *Panthera tigris* in Royal Chitwan National Park, Nepal. Contribution to Zoology 336. Smithsonian Institution, Washington, D.C.

Smith, J. L. D., McDougal, C., and Miquelle, D. (1989) Communication in free-ranging tigers (Panthera tigris). *Animal Behavior* 37:1–10.

Udvardy, M.D.F. (1975) A classification of the biogeographical provinces of the world. Morges (Switzerland): International Union of Conservation of Nature and Natural Resources. IUCN Occasional Paper No. 18.

Motaleb, M.A, Sayad, M., Sobhan, I. (2011) The Asian elephants and associated human-elephant conflict in South-eastern Bangladesh. IUCN Bangladesh Country Office, Dhaka. 118 pp

Zhang L, Dong L, Lin L, Feng L, Yan F, Wang L, et al. (2015) Asian Elephants in China: Estimating Population Size and Evaluating Habitat Suitability. PLoS ONE 10(5): e0124834. doi:10.1371/journal.pone.0124834

Naha D, Jhala YV, Qureshi Q, Roy M, Sankar K, Gopal R (2016) Ranging, Activity and Habitat Use by Tigers in the Mangrove Forests of the Sundarban. PLoS ONE 11(4): e0152119.doi:10.1371/journal.pone.0152119

Y. Qin, P.J. Nyhus, C.L. Larson, C.J. Carroll, J. Muntifering, T.D. Dahmer, L. Jun, R.L. Tilson (2015) An assessment of south China tiger reintroduction potential in Hupingshan and Houhe National Nature Reserves, China. Biol. Conserv., 182 (2015), pp. 72-86